សមាគមបុគ្គលិកសិក្សាខ្មែរ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ទស្សនាវដ្តី លេខ ៥

# គ្រូបង្រៀន




ខែតុលា - វិច្ឆិកា - ធ្នូ ១៩៩៦

ផ្សាយចេញរាល់ត្រីមាស ពិទិចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ

១៣៨ B. មហាវិថីព្រះនរោត្តម ( ភ្នំពេញ )

ទូរស័ព្ទ : ០១៥ ៩១៨ ១២៤

## I - គណៈកម្មការដំរង់ទិស - អំណាន និងតាមដាន

1 - លោក យ៉ឹង ធី ប្រធាន

2 - លោក ស៊ិន ងួនហេង សមាជិក

3 - លោក ណាត ប៊ុនរឿន សមាជិក

4 - លោក ធ សោ សមាជិក

5 - លោក ជា ជាតិ សមាជិក

6 - លោក ស៊ុង វ៉ាន់ថន សមាជិក

7 - លោកស្រី ហួរ សិរី សមាជិក

8 - លោក សង់ មីសែលឡឺប៊ុច សមាជិក

9 - លោក សេវា វីទូ សមាជិក

## II - គណៈកម្មការតែងអត្ថបទ

1 - លោក យ៉ឹង យ៉ាណូ

2 - លោក ឆយ យីហកឹង

3 - លោក អ៊ុម កុច

4 - លោក កង ឱម

5 - លោក ពត សុត

6 - លោក ផិន សុកហេង

7 - អ្នកស្រី ជាន់ សំអោ

8 - អ្នកស្រី អ៊ិច សារ៉ូ

9 - លោក សំអាន សាយ

10 - លោក ប្រាក់ ព្រុំ

11 - លោកអធិការបឋមសិក្សានៅគ្រប់ខេត្ត - ក្រុង
បណ្ដុះបណ្ដាលនៅមហាវិទ្យាល័យគរុកោសល្យ

ទស្សនាវដ្ដីនេះបោះពុម្ពដោយមានការរួមចំណែកជាបច្ចេកទេស និងហិរញ្ញវត្ថុ
ពី **កម្មវិធីទ្រទ្រង់ផ្នែកអប់រំបឋមសិក្សានៅកម្ពុជារបស់សហគមន៍អឺរ៉ុប**

Revue publiée avec le concours technique et financier
du Programme d'Appui au Secteur de l'Education Primaire
au Cambodge ( PASEC ) de l'Union Européenne.

# មាតិកាអត្ថបទ


១ - អារម្ភកថា

២ - សេចក្តីអំពាវនាវរបស់គណៈកម្មាធិការនាយក ស.ប.ស.ខ.

៣ - ពត៌មាន

- ទស្សនកិច្ចនៅប្រទេសបារាំង
- សាលារៀនខ្ញុំបានផ្លាស់ប្តូរហើយ
- ការប្រលងប្រទាំងកីឡា និង សិល្បៈឆ្នាំ ១៩៩៧
- សេចក្តីសំរេចរបស់មហាសន្និបាត ស.ប.ស.ខ ឆ្នាំ ១៩៩៦

៤ - វប្បធម៌ទូទៅ - ការអប់រំ

- វិវឌ្ឍន៍នៃទស្សនទានអប់រំ
- ជំនាក់នៃការអប់រំ និង ដំបូន្មានចំពោះឪពុកម្តាយ និង អ្នកអប់រំ
- អំពើប្រល័យពូជសាសន៍ក្នុងសកលលោក
- វិញ្ញាសាប្រលងជ្រើសរើសនិស្សិតអធិការបឋមសិក្សាជំនាន់ទី ៣

៥ - គរុកោសល្យ - ការគ្រប់គ្រង

- ដើម្បីបង្រៀនមេរៀនមួយបានល្អ តើលោកគ្រូ - អ្នកគ្រូ ត្រូវពិចារណាលើបញ្ហាអ្វីខ្លះ
- ការជ្រើសរើស និងការអនុវត្តវិធីសាស្ត្រនៃការបង្រៀន
- វិទ្យាសាស្ត្រអនុវត្តស្តីពីទឹក រំហួត បំនិត
- ការបង្រៀនមេលេខ
- ហេតុអ្វីបានជាយើងស្វាប ?

៦ - វេទិកាស្វែរិន

- សំនួរបញ្ហា
- សំនួរបង្កើនចំនេះដឹង
- ចំលើយ សំនួរ និង ដំនោះស្រាយល្បែងផិះសេះ
- ដំណឹងមរណភាព

# អារម្ភកថា

ក្នុងឆ្នាំសិក្សា ១៩៩៥- ៩៦ កន្លងទៅនេះ ទស្សនាវដ្ដីគ្រូបង្រៀនបានចេញផ្សាយទៅគ្រប់គ្រឹះស្ថានសិក្សានៅទីក្រុង និងនៅជនបទ ។ លោកគ្រូ - អ្នកគ្រូបឋមសិក្សាបានទទួលគ្រប់ៗគ្នា តែគួរអោយស្ដាយ ដោយទស្សនាវដ្ដីមានចំនួនកំនត់ដែលពុំអាចចែកជូនដល់អស់លោកសាស្ត្រាចារ្យបឋមភូមិ ទុតិយភូមិនៅអនុវិទ្យាល័យ វិទ្យាល័យ មហាវិទ្យាល័យ និងនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ។ ដំបូងឡើង គោលដៅរបស់យើងគឺចែកជូនគ្រូបឋមសិក្សាអោយបានគ្រប់ៗគ្នា ។ រីឯអនុវិទ្យាល័យ វិទ្យាល័យ មហាវិទ្យាល័យ និង នាយកដ្ឋានក្រោមឱវាទក្រសួងអប់រំ យុវជន និង កីឡា ត្រូវបានចែកជូនសំរាប់ដាក់ជូនអាន តែនៅក្នុងបណ្ណាល័យប៉ុននោះ ។ តែទោះជាយ៉ាងណាក៏ដោយ ជាទូទៅទស្សនាវដ្ដីគ្រូបង្រៀនបានចែកជូនទៅគ្រប់ស្ថាប័នអប់រំអស់ហើយ ត្រង់ថា បានអានគ្រប់គ្នា រឺមិនបានអាននោះ ជាបញ្ហាមួយដោយឡែក ។ យើងខ្ញុំមានបំនងប្រាថ្នាចង់អោយបានអានទាំងអស់គ្នា ដើម្បីអោយបានជ្រួតជ្រាបពតិមានផ្សេងៗពី ៖

១ - សមាគមបុគ្គលិកសិក្សាខ្មែរ

២ - ការអប់រំទូទៅ ( គរុកោសល្យ រដ្ឋបាល ការគ្រប់គ្រង )

៣ - កិច្ចការរដ្ឋបាលរបស់ក្រសួងអប់រំ យុវជន និង កីឡា

មកទល់ពេលនេះ យើងខ្ញុំមិនបានពតិមានពីមូលដ្ឋានគ្រូនៅឡើយ ចំពោះខ្លឹមសារ អត្ថរូប និងអត្ថរសនៃអត្ថបទចុះផ្សាយ ។ យើងខ្ញុំបានបើកវេទិកាស្វែរិន និងបានផ្ញើសេចក្ដីអំពាវនាវទៅគ្រប់ស្ថាប័នអប់រំ ដើម្បីសុំមតិយោបល់ និងសុំសំនេរទាក់ទងការងារអប់រំ ក៏ប៉ុន្តែគំនិតរិះរេចនា (Esprit critique) មានតិចតួចណាស់ ។ យើងខ្ញុំបានទទួលលិខិតដែលសុទ្ធតែមានអត្ថន័យអបអរសាទរ ដោយឃើញទស្សនាវដ្ដីគ្រូបង្រៀនរស់ឡើងវិញ ដែលភាគច្រើនជាមតិរបស់គ្រូជំនាន់មុនឆ្នាំ ១៩៧៥ ដែលនៅសេសសល់ ។ រីឯគ្រូជំនាន់ក្រោយឆ្នាំ ១៩៧៩ មានចំនួនតិចណាស់ ដែលបានផ្ញើលិខិតមកថ្លែងមនោសញ្ចេតនារីករាយដោយបានអានទស្សនាវដ្ដីគ្រូបង្រៀន និងបានធ្វើសំនូមពរខ្លះៗ ដោយអោយទស្សនាវដ្ដីចុះផ្សាយអត្ថបទអោយបានច្រើនពាក់ព័ន្ធទៅនឹងវប្បធម៌ទូទៅ ។ យើងខ្ញុំមានមោទនៈចំពោះការវាយតំលៃឥតលាក់លៀមទៅលើខ្លឹមសារអត្ថបទ ។ បុគ្គលិកសិក្សាយើងមួយចំនួន បានសំដែងមនោសញ្ចេតនា ដោយបញ្ចេញមតិផ្ទាល់មាត់ ដោយមិនបានស្គាល់យើងខ្ញុំជាស្នេរឡើយ ។ ម្យ៉ាងទៀត តាមរយៈអ្នកឆ្លើយឆ្លងរបស់គំរោងកម្មវិធីប៉ាសិចទៅតាមខេត្ត - ក្រុងមួយចំនួនគាត់បានវាយតំលៃដោយសុទ្ធចិត្តថា ទស្សនាវដ្ដីគ្រូបង្រៀន ជាឧបករណ៍មួយដ៏មានប្រសិទ្ធភាព ចំពោះការលើកតំកើងវប្បធម៌ទូទៅ និង គរុកោសល្យរបស់គ្រូបង្រៀន ។ យើងខ្ញុំសប្បាយរីករាយ ដោយបានធ្វើអោយសំរេចជាជំហានៗនូវគោលដៅរបស់សមាគមបុគ្គលិកសិក្សាខ្មែរ ក្នុងការជួយផ្ដល់ រឺផ្ទេរចំនេះដឹងទៅអោយគ្រូយើង ក្រៅពីបានជួយឧបត្ថម្ភវាងហិរញ្ញវត្ថុនៅពេលសមាជិកអនិច្ចកម្ម ។

យើងខ្ញុំរីករាយនឹងជំរាបលោកគ្រូ - អ្នកគ្រូថា នៅមុនពេលចាប់ផ្ដើមបន្តបោះពុម្ពផ្សាយទស្សាវដ្ដីឆ្នាំទី២ គឺចាប់ពីលេខ ៥ ទៅ យើងខ្ញុំបានចុះហត្ថលេខាលើអនុសញ្ញា (Convention) ជាមួយគំរោងកម្មវិធីប៉ាសិច ដែលបានយល់ព្រមដោយស្មោះស្ម័គ្រអោយយើងខ្ញុំបោះពុម្ពទស្សនាវដ្ដីបន្ថែមពីឆ្នាំចាស់ ចំនួនប្រាំពាន់ក្បាលទៀត រួមមាន ៦៥.០០០ ក្បាល ក្នុងមួយលេខៗ ។ លោកនាយកកម្មវិធីបានផ្ដាំថា ទស្សនាវដ្ដី ៥០០០ ក្បាលក្រោយនេះ គឺសំរាប់ចែកជូនទៅអនុវិទ្យាល័យ វិទ្យាល័យ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ។

ជាថ្មីម្ដងទៀតសូមលោកអ្នកអាន មេត្តាផ្ដល់មតិយោបល់និងសូមសរសេរអត្ថបទអប់រំសំរាប់គ្រូយើងទាំងអស់គ្នា ។

**គ.នាយក ស.ប.ស.ខ**

# សេចក្ដីអំពាវនាវ
# របស់គណៈកម្មាធិការនាយកនៃសមាគមបុគ្គលិកសិក្សាខ្មែរ

ទស្សនាវដ្ដីគ្រូបង្រៀន ជាទស្សនាវដ្ដីរបស់គ្រូទាំងអស់គ្នា ។លោកគ្រូ - អ្នកគ្រូម្នាក់ៗមានសិទ្ធិសរសេរបញ្ចេញមតិយោបល់ទាក់ទងនឹងការអប់រំកុលបុត្រ កុលធីតា ។ បុគ្គលិកសិក្សាទាំងអស់ដែលបំរើការអប់រំ មិនមែនគ្រាន់តែចង់បានបៀវត្សបន្តិចបន្តួចសំរាប់ទ្រទ្រង់ជីវិតប៉ុណ្ណោះទេ តែនៅមានចិត្តចង់ជួយជាតិ ស្នេហាវប្បធម៌ជាតិ ចង់អោយប្រជាពលរដ្ឋមានចំនេះដឹងគ្រប់ៗគ្នា គឺកុំអោយភាពល្ងង់ខ្លៅសង្កត់សង្កិនខ្លាំងហួសប្រមាណ ។ ថ្វីត្បិតតែជីវភាពរស់នៅមានការលំបាកនៅឡើយ ដូចសព្វថ្ងៃនេះក្ដី ក៏មនសិការជាតិ មនសិការវិជ្ជាជីវៈ នៅមិនទាន់សាបសូន្យអស់ពីសន្ដានចិត្តនៃគ្រូយើងឡើយ ។

ដើម្បីជាគុណប្រយោជន៍ដ៏ឧដុង្គឧត្តមចំពោះសង្គមខ្មែរ អ្នកមានគំនិតល្អ និងមានបទពិសោធន៍ខ្ពស់ទាំងឡាយក្នុងការបង្រៀន គួរតែជួយដាស់តឿនគ្នា អប់រំគ្នា ជួយផ្ទេរចំនេះដឹងអោយសហសេវិក ( collègue ) ដើម្បីពង្រីកពង្រឹងគុណភាពបង្រៀន ឈានទៅសំរេចគោលដៅអប់រំដ៏ពិសិដ្ឋរបស់យើង ។

អត្ថបទដែលមានខ្លឹមសារគ្រប់គ្រាន់ល្មមចុះផ្សាយ ត្រូវបានទទួលរង្វាន់បួន (៤) ដុល្លាអាមេរិកក្នុងមួយទំព័រវាយកុំព្យូទ័រ ( ខ្នាត A4 ) ។

យើងខ្ញុំចង់បានជាពិសេស នូវវិធីសាស្ត្រនៃការបង្រៀនមេរៀនអ្វីមួយ ក្នុងមុខវិជ្ជាសិក្សាសង្គមវិទ្យា រឺ វិទ្យាសាស្ត្រអនុវត្ត សំរាប់ថ្នាក់ណាមួយនៅបឋមសិក្សា ( Conduite d'une leçon de sciences sociales ou de sciences appliquées des différents niveaux du cycle primaire ) ។

ដូចនេះ យើងខ្ញុំសូមអំពាវនាវដល់ទឹកចិត្តស្នេហាគ្រូបង្រៀន សូមលោកគ្រូ អ្នកគ្រូ មេត្តាជួយជ្រោមជ្រែងទស្សនាវដ្ដីគ្រូបង្រៀន ដោយបញ្ចេញបទពិសោធន៍ល្អៗ ដល់ជួរបុគ្គលិកសិក្សាយើង ។ ទង្វើនេះ ជាកាតព្វកិច្ចសង្គមវប្បធម៌ ដែលបុគ្គលម្នាក់ៗត្រូវបំពេញជាដាច់ខាត ដើម្បីអនាគតរុងរឿងនៃព្រះរាជាណាចក្រកម្ពុជា ។

## ជយោ! សាមគ្គីភាព

# ទស្សនកិច្ចនៅប្រទេសបារាំង

ក្នុងការប្រលងប្រណាំងថ្នាក់ជាតិ ដណ្តើមយកជ័យលាភីប្រចាំឆ្នាំ ១៩៩៦ ផ្នែកកីឡា បានទៅសាលាបឋមសិក្សាត្រពាំងថ្ម ខេត្តកំពង់ឆ្នាំង ឯផ្នែកសិល្បៈត្រូវបានទៅសាលាបឋមសិក្សាសន្ធរម៉ុក រាជធានីភ្នំពេញ ។ លោកនាយកនៃសាលាទាំងពីរ ត្រូវបានទទួលរង្វាន់លើកទឹកចិត្ត អោយទៅធ្វើទស្សនកិច្ចនៅប្រទេសបារាំង និងចូលរួមក្នុងពិធីបុណ្យខួបលើកទិ ៥០ ឆ្នាំ នៃមជ្ឈមណ្ឌលសិក្សាគរុកោសល្យអន្តរជាតិ នៅទីក្រុងប៉ារីស ឧបត្ថម្ភដោយថវិការបស់ការិយាល័យវប្បធម៌ អមស្ថានទូតបារាំងប្រចាំកម្ពុជា ។



គណៈប្រតិភូរួមមាន ៖

- លោកស្រី ហួរ ស៊ីរី ប្រធានស្ដីទីនាយកដ្ឋានបណ្ដុះបណ្ដាល និង វិក្រឹតការនៃក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគណៈកម្មការឈានមុខរបស់ប៉ាសិច ។
- លោក ឈៀក ខែម នាយកសាលាបឋមសិក្សាសន្ធរម៉ុក រាជធានីភ្នំពេញ ។
- លោក អ៊ុច ហួ នាយកសាលាបឋមសិក្សាត្រពាំងថ្ម ខេត្តកំពង់ឆ្នាំង ។
- លោក ស៊ាង ស្រេង សមាជិកនៃសមាគមបុគ្គលិកសិក្សាខ្មែរ ។

បុណ្យខួបលើកទី ៥០ ឆ្នាំនេះ បានប្រព្រឹត្តទៅអស់រយៈពេល ៣ ថ្ងៃ ចាប់ពីថ្ងៃទី ១១ ដល់ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ១៩៩៦ ។ សកម្មភាពដ៏មហោឡារិក មានអត្ថន័យ និងមានសារៈសំខាន់ដ៏ធំធេងនេះ បានធ្វើការតាំងពិពណ៌ស្ដីពីសកម្មភាពរបស់កម្មវិធីប៉ាសិចនៃសហភាពអឺរ៉ុប ។

ក្នុងបន្ទប់មួយដ៏ធំ មានតាំងផែនទីនៃប្រទេសកម្ពុជា អមដោយទង់ជាតិប្រចាំប្រទេស និងទង់ជាតិរបស់សហភាពអឺរ៉ុប ។ សំភារៈឧបទេស ដូចជា បន្ទាត់កែង ។ ល ។ ព្រមទាំងឯកសារបណ្ដុះបណ្ដាលពីចំងាយ ទស្សនាវដ្ដីគ្រូបង្រៀន ទស្សនាវដ្ដីសំរាប់កុមារ ដែលរៀបចំយ៉ាងប្រណិត និងមានការបញ្ចាំងទូរទស្សន៍បង្ហាញពីសកម្មភាពកម្មវិធីប៉ាសិចគ្រប់ផ្នែកទាំងអស់ ព្រមទាំងមានការពន្យល់យ៉ាងក្បោះក្បាយ ដែលធ្វើអោយទស្សនិកជនមានការចាប់អារម្មណ៍យ៉ាងខ្លាំង ។



នៅថ្ងៃទី ២ នៃបុណ្យខួបនេះ មានបើកការប្រជុំមួយនៅក្នុងបន្ទប់ពិព័រណ៌ ក្រោមអធិបតីភាពនៃលោកនាយកមជ្ឈមណ្ឌល ។ ក្នុងចំណោមភ្ញៀវកិត្តិយសជាច្រើន មានតំណាងឯកអគ្គរាជទូតខ្មែរប្រចាំនៅប្រទេសបារាំង ២ រូបបានចូលរួមផងដែរ ។ លោក ហ្សៀវីរិន្ទ ទីប្រឹក្សាបច្ចេកទេស អមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លោក ហ្វ្រង់ស្វ័រហ្វេមីញ៉ា ជំនាញការកម្មវិធីប៉ាសិចប្រចាំក្រុងភ្នំពេញ និងភូមិភាគដាច់ស្រយាល បានពន្យល់អង្គប្រជុំអំពីសកម្មភាពអង្គការប៉ាសិច និងការរីកចំរើនលើវិស័យអប់រំក្នុងប្រទេសកម្ពុជា ។

បន្ទាប់មក លោកស្រី ហួរ ស៊ីរី បានជំរាបអង្គប្រជុំអំពីផលប្រយោជន៍នៃជំនួយរបស់កម្មវិធីប៉ាសិចផ្នែកបណ្តុះបណ្តាលគ្រូឧទ្ទេស បណ្តុះបណ្តាលពីចំងាយដែលបានលើកកំពស់ចំនេះដឹង វិទ្យាសាស្ត្របច្ចេកទេស ចំនេះដឹងចិត្តគរុកោសល្យ និងកំរិតជីវភាពគ្រូចំនួន ៤៥.០០០ នាក់ ។ កម្មវិធីប៉ាសិច បានផ្តល់សំភារៈឧបទេសដល់សាលាបឋមសិក្សាចំនួន ៥០០០ និងបានធ្វើអោយសហគមន៍មានជំនឿលើសាលារៀន ។ លោក ឈៀក ខែម និង លោក អ៊ុច ហួ នាយកសាលាទាំងពីរក៏បានថ្លែងនូវការរីកចំរើនក្នុងសាលារបស់លោកដោយជំនួយកម្មវិធីប៉ាសិចផងដែរ ។



ក្នុងឱកាសនោះដែរ លោក ស៊ាង ស្រេង ជាសមាជិកគណៈប្រតិភូ និងជាអ្នកតំណាងសមាគមបុគ្គលិកសិក្សាខ្មែរ បានជំរាបដល់អង្គប្រជុំបានជ្រាបពីដំណើរការផលិតទស្សនាវដ្តីគ្រូបង្រៀន ដែលឧបត្ថម្ភដោយកម្មវិធីប៉ាសិច ដែលមានលោក មីសែល ឡឺប៊ុច ជាប្រធាន លោក ហ្សេរ៉ារីនូ ជាទីប្រឹក្សាបច្ចេកទេសអមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងលោក ហ្វ្រង់ស្វ័រហ្វេមីញ៉ា ដែលជាអ្នកសំរបសំរួលការងារដោយផ្ទាល់ ។ ទស្សនាវដ្តីនេះ បានផ្តល់ផលប្រយោជន៍ដ៏សំខាន់រួមចំណែកដល់ការលើកកំពស់គុណភាពចំណេះដឹងគ្រូបង្រៀនទូទាំងប្រទេស ។

ក្រៅពីការចូលរួមពិធីបុណ្យខួបលើកទី ៥០ ឆ្នាំ នៃមជ្ឈមណ្ឌលសិក្សាគរុកោសល្យអន្តរជាតិនេះ គណៈប្រតិភូបានទៅធ្វើទស្សនកិច្ចដកពិសោធន៍ការងារបណ្តុះបណ្តាល និងវិក្រិតការគ្រូបង្រៀន ការបណ្តុះបណ្តាលបច្ចេកទេសវិទ្យាកំរិតមធ្យម ដល់យុវជនមធ្យមសិក្សាកំរិត ១ + ២ និងជាពិសេស ការបង្រៀនក្នុងថ្នាក់មួយដែលមានកំរិតខុសៗគ្នា តាំងពីកំរិតមត្តេយ្យ ដល់ថ្នាក់ទី ៤ នៅខេត្តឡុន (Laon) ក្នុងភូមិមួយដែលសាលារៀនមានតែមួយថ្នាក់ ។

ទស្សនកិច្ចនេះ បាននាំមកនូវផលប្រយោជន៍សំខាន់សំរាប់វិស័យអប់រំទាំងមូល ជាពិសេសទស្សនកិច្ចនេះ បានធ្វើអោយចំណងសាមគ្គីភាព មិត្តភាព និងសហប្រតិបត្តិការកាន់តែរឹងមាំពីសំណាក់កម្មវិធីប៉ាសិចនៃសហគមន៍អឺរ៉ុបចំពោះកម្ពុជា ។

**ដោយ លោក ស៊ាង ស្រេង**

# សាលារៀនខ្ញុំបានផ្លាស់ប្ដូរហើយ

កាលពីឆ្នាំទៅមិញ អ៊ុក គេទី អាយុ ១១ ឆ្នាំ ជាសិស្សសាលាបឋមសិក្សា ។ ថ្ងៃនេះ នាងបានក្លាយទៅជាតួឯកម្នាក់ ទៅតាមទេពកោសល្យ និងបច្ចេកទេសសំដែងរបស់នាង ។ នាងមានឈ្មោះល្បីនៅក្នុងសាលារៀន មានប្រជាប្រិយភាពជាមួយនឹងមិត្តភក្ដិ ហើយនាងក៏មានកេរ្តិ៍ឈ្មោះនៅក្នុងភូមិឃុំដែរ ។ បន្ថិចទៀត នាងនឹងត្រូវចេញមុខជាច្រើនដងនៅក្នុងទូរទស្សន៍ ហើយត្រូវបានទូរទស្សនិកជនមើលឃើញនាងតាមកញ្ចក់ទូរទស្សន៍នៅគ្រប់សាលារៀនទូទាំងប្រទេស ។ នាងបាននិយាយប្រាប់គេថា « សាលារៀនខ្ញុំមានការផ្លាស់ប្ដូរហើយ ។ នាងខ្ញុំអាចនិយាយប្រាស្រ័យទាក់ទងបានកាន់តែប្រសើរ ជាមួយអស់លោកជាគ្រូបង្រៀននាងខ្ញុំ » ។ ឥលូវនេះ បណ្ដាមិត្តភក្ដិនាងខ្ញុំក៏ដូចជា ឪពុកម្ដាយនាងខ្ញុំមានមោទនភាពណាស់ ចំពោះតួនាទីនាងខ្ញុំនៅក្នុងសង្គម » ។ ដោយសារការដើរតួជាសិល្បករ ធ្វើជានារីស្រែកស្រែទូលចេកលក់នៅតាមផ្លូវ ហើយត្រូវចាញ់បោកសត្វទន្សាយ ដែលមានចរិតរប៉ិលរប៉ូចនោះ នាងកេទី និងមិត្តភក្ដិឯទៀតក្នុងក្រុមរបស់នាង ដែលចេញពីសាលាបឋមសិក្សាសន្ធរម៉ុក បានទទួលរង្វាន់ជ័យលាភីលេខ១ នៅក្នុងពិធីមហោស្រពសាធារណៈ ដែលគេរៀបចំឡើងដោយគណៈមេប្រយោគអោយពិន្ទុ ។ នាងបានដើរចេញមកទទួលរង្វាន់ជ័យលាភីលេខ១ ខាងផ្នែកសិល្បៈ មានតំលៃជាទឹកប្រាក់ ៤.០០០ $ ក្នុងការប្រលងប្រជែងខាងវិស័យវប្បធម៌ ដែលចាត់ចែងឡើងដោយក្រសួងអប់រំ យុវជន និងកីឡា ។



លោក ឈៀក ខែម នាយកសាលាបានមានប្រសាសន៍ថា « យើងកសាងសាលមហោស្រពថ្មីមួយ និងបណ្ណាល័យមួយ ដោយចំនាយលុយកាក់បានពីរង្វាន់នេះ ។ យើងមានសៀវភៅគ្រប់មុខ ដូចជាសៀវភៅសំរាប់គ្រូបង្រៀន ឯកសារសិក្សា រឿងនិទាន ។ គ្រូបង្រៀនលើកទឹកចិត្តសិស្សអោយចេះប្រើប្រាស់បណ្ណាល័យ និងចូលទៅសិក្សាស្រាវជ្រាវក្នុងបណ្ណាល័យ ។ លុយកាក់មួយផ្នែក ត្រូវបានយកទៅប្រើប្រាស់ផងដែរ សំរាប់ជួសជុលក្រាលការ៉ូនៅក្នុងថ្នាក់រៀន ដាក់បង្អួចនិងទ្វារឡើងវិញ ហើយនិងកែលំអទីធ្លានៅជុំវិញសាលារៀន ។ លោកនាយកបានមានប្រសាសន៍ទៀតថា « ពីមុន



សិស្សមិនអាចលេងកំសាន្តបានទេ ពីព្រោះទីធ្លាសាលាមិនទាន់បានរៀបចំអោយល្អ តែឥលូវនេះ សិស្សមានកន្លែងសំរាប់លេងកំសាន្តនៅពេលចេញលេង ។ ពីមុនសិស្សឯទៀតៗ មិនសូវចូលចិត្តនឹងល្ខោនទេ ហើយក៏មិនចាប់អារម្មណ៍នឹងកីឡាដែរ ។ ប៉ុន្តែឥលូវនេះ គេចាប់អារម្មណ៍នឹងវិស័យទាំងនេះណាស់ ។ សិស្សចង់អោយគ្រូបង្រៀន និងនាយកសាលារៀបចំអោយបានល្អថែមទៀត នៅពេលប្រលងប្រជែងសិល្បៈលើកក្រោយ ។

ទីធ្លានៃថ្នាក់រៀន ត្រូវបានចាក់ដីកំពស់ ៣០ cm ។ ដោយសេចក្ដីសង្ឃឹមថា នៅឆ្នាំក្រោយនេះ យើងមានថ្នាក់រៀន ដែលទឹកជំនន់មិនអាចប៉ះពាល់បាន ។ ដោយសារហេតុផលនៃកំនែលំអនេះហើយ យើងមានលទ្ធភាពបង្កើនការសិក្សានៅក្នុងសាលារៀនយើង ។ កាលពីឆ្នាំទៅមិញ យើងរៀនបានតែពីរពេល ប៉ុន្តែឆ្នាំនេះ បានបីពេល គឺពីម៉ោង ៦,៣០ ទៅ ១០,៣០ ពី ១០,៣០ ទៅ ១២,០០ និងពីម៉ោង ២,៣០ ទៅ ៥,៣០ ។

នៅក្នុងវ័យ ១១ ឆ្នាំដូចគ្នានេះ សុន ស៊ីណុន និង ថន នៀន បានធ្វើដំនើរទៅភ្នំពេញជាលើកដំបូង បានចូលគាល់ព្រះមហាក្សត្រ ហើយបានធ្វើអោយគេចាប់អារម្មណ៍យ៉ាងខ្លាំងក្លាបំផុត អំពីអ្វីៗដែលគេបានចូលរួមកាលពីឆ្នាំមុន ។ ក្រុមសិស្សពីសាលាសាមគ្គី ស្រុកមានជ័យ ខេត្តកំពង់ឆ្នាំង បានទទួលរង្វាន់ជ័យលាភីលេខ១ ក្នុងការប្រកួតកីឡា ។ ថន់នៀន បាននិយាយថា : « ខ្ញុំសប្បាយចិត្តណាស់ ដោយបានមកភ្នំពេញ ។ នេះជាលើកដំបូងរបស់ខ្ញុំហើយ ។ មានកន្លែងច្រើនណាស់ដែលត្រូវដើរ មើលកំសាន្តក្នុងរាជធានីភ្នំពេញ ហើយពិសេស ខ្ញុំមិនធ្លាប់បានចូលរួមក្នុងមហាពិធីណាមួយដូចនេះទេ ។ នេះជាលើកដំបូងហើយដែលខ្ញុំបានចូលរួមមើលសណ្ឋាគារកាំបូឌីយ៉ាណា ហើយបានជួបព្រះមហាក្សត្រ និងចូលគាល់ព្រះអង្គទៀតផង » ។ សុន ស៊ីណុនបាននិយាយថា : « ខ្ញុំបានជួប និងចងសម្ព័ន្ធមិត្តជាមួយនឹងមិត្តភក្តិជាច្រើនមកពីខេត្តកំពង់ធំ កំពង់ស្ពឺ បាត់ដំបង ព្រៃវែង និងតាកែវ » ។

ឥលូវនេះ សាលារៀនរបស់គេមានបង្គន់អនាម័យទើបសង់ថ្មី ដោយសារតែលុយកាក់ដែលគេបានឈ្នះរង្វាន់ជ័យលាភីខាងវិស័យកីឡា ។



លោកគ្រូ គុំ ឡែម បានមានប្រសាសន៍ថា មុនដំបូងសិស្សបានគិតថា ប្រាក់រង្វាន់ជ័យលាភីនេះសំរាប់ខ្លួនគេផ្ទាល់ ។ គាត់បានមានប្រសាសន៍ទៀតថា : នៅក្រោយការប្រកួតប្រជែង សិស្សយល់ដឹងថា លុយកាក់ទាំងនោះ ត្រូវបានគេយកទៅប្រើប្រាស់សំរាប់កែលំអក្នុងសាលារៀន ដូចជា ទីលានបាល់ទាត់ ហើយពួកគេសប្បាយចិត្តណាស់ ដោយបានឃើញប្រាក់ទាំងអស់ ត្រូវបានយកទៅប្រើប្រាស់សំរាប់សិស្សទាំងអស់គ្នា មិនមែនសំរាប់តែក្រុមគេប៉ុន្មាននាក់នោះឡើយ ។ ឥលូវនេះគេយល់ថា តើការងារសមូហភាព និងការងារតាមក្រុម មានផលប្រយោជន៍យ៉ាងណានោះ ? ។

លោក អ៊ុច ហួ នាយកសាលាបានមានប្រសាសន៍ថា មុនពេលប្រលងប្រជែង សាលារៀនយើងមានតែអាគារសង់អំពីឈើទេ តាំងពីអោយមានការប្រកួតប្រជែងមក យើងទទួលបានលុយកាក់ខ្លះពីមូលនិធិអាស៊ី ហើយសាងសង់បានសាលារៀនថ្មីមួយ ។ ដោយសារលុយកាក់បានមកពីការប្រកួតប្រជែងនេះហើយ យើងកសាងបានបង្គន់អនាម័យមួយក្នុងសាលារៀន ទិញតុថ្មីសំរាប់ដាក់ក្នុងថ្នាក់រៀន ហើយយើងចិញ្ចឹមជ្រូក ៧ សំរាប់យកកំរៃជូនដល់គ្រូបង្រៀន ។ ឪពុកម្ដាយសិស្សបានចំនាយកំលាំងកាយរបស់គេដើម្បីជួយកសាងបានជា ទីលានបាល់ទាត់ និងបាល់ទះ ។ ដោយបានឃើញការកែលំអសព្វបែបយ៉ាងក្នុងសាលារៀន ឥលូវនេះគេកំពុងប្រមើលមើល ដើម្បីកសាងរបងសាលារៀនថែមទៀត ។


សាលារៀនយើងបាន ឈ្នះគេ ព្រោះតែខ្ញុំបាន បង្ហាត់សិស្សខ្ញុំ
ពិតណាស់ សាលារៀន យើងបានឈ្នះគេ
យើងទាំងអស់គ្នា ព្រមទាំងឪពុក ម្ដាយយើង បានរួមចំណែក អោយសាលារៀនបានឈ្នះគេ
ដោយសហការគ្នាយ៉ាងជិតស្និទសិស្សគ្រូ និងឪពុកម្ដាយសិស្សបានរួមកំលាំងយក ជ័យជំនះរបស់សាលារៀនយើង
នៅឆ្នាំនេះទៀត ក្រសួង អ.យ.ក នឹងរៀបចំការប្រលងប្រណាំងកីឡា និងសិល្បះមួយយ៉ាងធំ ។ ដើម្បីអោយសាលាអ្នកទទួលជ័យជំនះ ចូរ អ្នកហ្វឹកហាត់ពីឥលូវនេះទៅ ហើយចូលរួមប្រកួតផ្ដាច់ព្រ័ត្រនៅក្នុងស្រុក អ្នក ខេត្តអ្នក ហើយនៅរាជធានី នៅខែឧសភាក្រោយ ។
ការប្រលងប្រណាំងមួយទៀត ដែលដាក់ឈ្មោះថា ‹‹ សាលាយើងបានប្រែមុខមាត់ ›› នឹងជូនរង្វាន់សាលារៀនណា នឹងសហគមន៍ណា ដែលបានរួមជួយដាក់កំលាំងក្នុងការលើកកំពស់គុណភាពអប់រំ ។ ចូរអ្នកចូលរួមពីពេលនេះទៅ ហើយអ្នកនឹងទទួលរង្វាន់មួយ ក្នុងចំនួនរង្វាន់ដ៏ច្រើន ដោយបង្ហាញប្រាប់ថា : ‹‹ សាលារៀនអ្នកបានផ្លាស់ប្ដូរមុខមា ត់ថ្មី ដោយហេតុតែការអប់រំជាភារកិច្ចយើងទាំងអស់គ្នា ››

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**********

សមាគមបុគ្គលិកសិក្សាខ្មែរ
លេខ : ០២ គ.ក
********

ភ្នំពេញ ថ្ងៃទី ១០ ខែ មករា ១៩៩៧

**ប្រធានគណៈកម្មាធិការនាយក សមាគមបុគ្គលិកសិក្សាខ្មែរ**

**ជំរាបមក**

**លោកប្រធាន គណៈកម្មាធិការ ស.ប.ស.ខ គ្រប់ខេត្ត - ក្រុង**

**កម្មវត្ថុ** : ការអនុវត្តន៍សេចក្តីសំរេចរបស់មហាសន្និបាត ស.ប.ស.ខ ឆ្នាំ ១៩៩៦
**យោង** : កំនត់ហេតុមហាសន្និបាត ស.ប.ស.ខ កាលពីថ្ងៃទី ២៦ - ១២ - ៩៦

ចំពោះកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោកប្រធានថា ចាប់ពីថ្ងៃ ១ ខែ មករា ១៩៩៧ តទៅ សមាគមបុគ្គលិកសិក្សាខ្មែរ ត្រូវអនុវត្តប្រការខ្លះក្នុងលក្ខន្តិកៈ និង បទបញ្ជាដែលមហាសន្និបាតបានកែសំរួល និង អនុម័តរួចហើយ នៅពេលមហាសន្និបាត ។

**ប្រការទី ៤៣ :** **កែឆ្នាំសិក្សា ជាឆ្នាំរដ្ឋបាល**
មហាសន្និបាតសាមញ្ញប្រជុំមួយឆ្នាំម្តង នៅចុងឆ្នាំរដ្ឋបាល ។
ចំនុចទី ១. ២ . ៣. ៤. ៥ នៃប្រការនេះ ត្រូវបានរក្សាទុកដដែល ។

**ប្រការទី ១ :** **( បទបញ្ជា )**
ចំនុច ខ :- ត្រូវដកចេញសិន មិនទាន់អនុវត្ត ចាប់ពីថ្ងៃ ០១-០១-៩៧ តទៅ ។
- ចំពោះសមាជិកដែលមានបញ្ហាដូចប្រការ ១ ចំនុច « ខ » ហើយដែលត្រូវក្រសួងសំរេចបញ្ឈប់ពីការងារ មុនថ្ងៃទី ០១-០១-៩៧ គណៈកម្មាធិការកណ្តាល ស.ប.ស.ខ នឹងរៀបចំគណៈកម្មការមួយ ចុះពិនិត្យជាក់ស្តែង ដើម្បីដាក់ជូនអង្គប្រជុំគណៈកម្មាធិការកណ្តាលសំរេច ។

ចំនុច ឃ : ( ថ្មី ) បើស្វាមី ភរិយា ជាសមាជិកទាំងពីរនាក់ ហើយទទួលមរណភាព ក្នុងពេលជាមួយគ្នា សាមីជនត្រូវទទួលអំនោយរៀងៗខ្លួន មួយលាន ប្រាំបួនសែន ប្រាំម៉ឺនរៀល ( ១.៩៥០.០០០រ ) គឺ ៖
- ១.៣០០.០០០រ ក្នុងឋានៈជាសមាជិក
- ៦៥០.០០០រ ក្នុងឋានៈជាប្តី រឺ ប្រពន្ធជាសមាជិក

**ប្រការទី ១៧ :** ( ថ្មី ) ( បន្ថែមក្នុងជំពូកទី ៥ ស្តីពីបញ្ញត្តិផ្សេងៗ ) គណៈកម្មាធិការខេត្ត - ក្រុង នៃសមាគមបុគ្គលិកសិក្សាខ្មែរ មានសិទ្ធិប្រើប្រាស់ត្រារបស់សមាគម ។

រាល់ខ្លឹមសារនៃប្រការផ្សេងៗ នៃលក្ខន្តិកៈ និង បទបញ្ជាត្រូវរក្សាទុកជាធរមាន ។

ចំលងជូន :
- ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីរអប់រំ យុវជន និងកីឡា គ្រប់ខេត្ត - ក្រុង
  « ដើម្បីជូនជ្រាបជាពត៌មាន »
- កាលប្បវត្តិ
- ឯកសារ

**យ៉ង់ ធី**




# វិវឌ្ឍន៍នៃទស្សនទានអប់រំ

## Evolution de la conception de l'Education

តាំងពីបុរាណកាលមកដល់សម័យកាលយើងនេះ គ្រប់ប្រទេសលើសកលលោក មានទស្សនទានអប់រំកុលបុត្រកុលធីតារបស់គេប្លែកៗគ្នា ទៅតាមជំនាន់ និងសង្គមរបស់ខ្លួន ។

នៅអឺរ៉ុប ចាប់តាំងពីប្លាតុង « ៤២៧ - ៣៤៨ មុនគ.ស » មក ការវិវត្តគំនិតអប់រំមានជាលំដាប់លំដោយរេទៅតាមគោលបំនងរបស់សង្គមខ្លួន ។ គេបណ្ដុះបណ្ដាលអោយទៅជាអ្នកចំបាំងដ៏ក្លាហាន ជាអភិជនចេះទំនៀមទំលាប់ ចេះរបៀបរបប និងចេះធ្វើបូកពាសមស្រប ។

នៅអាស៊ី នៅប្រទេសចិន និងវៀតណាម កាលពីជំនាន់ដើម គេជ្រើសរើសអ្នកមានចំនេះខាងអក្សរសាស្ត្រដោយការប្រលងប្រជែងក្នុងបីឆ្នាំម្ដង ដើម្បីធ្វើនាម៉ឺននៅក្នុងវាំង ។ នៅប្រទេសកម្ពុជាយើងនេះ ការបណ្ដុះបណ្ដាលផ្នែកអក្សរសាស្ត្រ និងសិល្បវិជ្ជា មានការរីកចំរើនគួរជាទីមោទនៈនៅសម័យអង្គរ ។ តាមឯកសារស្រាវជ្រាវ យើងបានដឹងថានៅក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ មានសាកលវិទ្យាល័យមួយដឹកនាំដោយព្រះនាងឥន្ទ្រទេវីជាអគ្គមហេសី ។ ក្នុងសម័យដ៏រុងរឿងនេះ មានអ្នកចេះអក្សរសាស្ត្រជ្រៅជ្រះ និងអ្នកនិពន្ធ អ្នកកវី ស្ថាបត្យករ វិស្វករ សិល្បករជាច្រើន ដែលអាចសាងសង់ប្រាសាទទាំងអស់នោះបាន ។ សិលាចារឹកទាំងឡាយ តែងតែអួតសរសើរពីគុណសម្បត្តិខាងបញ្ញា និងសីលធម៌របស់តួអង្គនានា មិនថាប្រុស រឺ ស្រី មិនថាស្ដេច រឺ រាស្ត្រឡើយ ។ ប៉ុន្តែ គួរអោយអាម៉ាស់ចំពោះប្រវត្តិសាស្ត្រខ្មែរចាប់ពីទសវត្សទី ១៣ មក ។ នេះបណ្ដាលមកពីខ្វះសីលធម៌ « លោភលន់បុណ្យសក្តិ មាសប្រាក់អយុត្តិធម៌សង្គមអំពើឃោរឃៅ » ។

ចាប់ពីក្រោយសម័យអង្គរ ប្រជារាស្ត្រខ្មែរនឿយណាយនឹងសង្គ្រាម នឿយណាយនឹងអយុត្តិធម៌សង្គម ឈប់មានជំនឿចំពោះខ្លួនឯងថានឹងរក្សាភាពត្រចះត្រចង់នេះបាន ។ ក៏ប៉ុន្តែ ប្រជារាស្ត្រខ្មែរមានជំនឿមួយថ្មីទៅលើពុទ្ធសាសនាថេរវាទ ។ អាស្រ័យហេតុនេះ ចាស់ៗទាំងប្រុស ទាំងស្រី ថ្វាយខ្លួនជាឧបាសក - ឧបាសិកាតាមពុទ្ធោវាទ ។ រីឯយុវជនត្រូវទៅរៀនអក្សរសាស្ត្រនៅវត្ត ។ លុះបានចេះដឹងហើយ គេត្រូវបួសជាសាមណេរ ។ លុះអាយុគ្រប់ ២១ ឆ្នាំ ត្រូវបំពេញជាភិក្ខុទៀត ។ សង្គមខ្មែរពេលនោះ រាប់រកអ្នកដែលបានបួសណាស់ ។ ពាក្យបណ្ឌិតដែលផ្ដល់អោយចំពោះអ្នកចាកផ្នួសមកវិញ ធ្វើជាគ្រហាវាស ជាពាក្យថ្លៃថ្នូរណាស់ ប្រសើរណាស់ ។ អ្នកមិនបានបួស មិនបានចេះអក្សរ

សង្គមខ្មែរមិនសូវរាប់រកទេ ។ ដូច្នេះ វត្តអារាមជាទីសក្ការបូជាផង និងជាមជ្ឈមណ្ឌលបណ្ដុះបណ្ដាលបញ្ញា សីលធម៌ និងសិល្បសាស្ត្ររបស់ប្រជាជនខ្មែរផង ។ អ្នកបណ្ឌិត ប្រសិនបើប្រកាន់ខ្ជាប់នូវចរិយាធម៌ល្អ មានអធ្យាស្រ័យល្អ អ្នកភូមិផង របងជាមួយគោរពរាប់អានលើកតំកើងជាគ្រូបាអាចារ្យក្នុងពិធីផ្សេងៗ ។ ដូច្នេះ យើងឃើញថា ទិសដៅអប់រំនៅពេលនោះ គឺស្វែងរកពុទ្ធិផង ចរិយាធម៌ផង និងសិល្បវិជ្ជាផង ។ នៅក្នុងរបបគ្រប់គ្រងប្រទេសកម្ពុជា ដោយអាណានិគមនិយមបារាំង ទិសដៅអប់រំបានងាកទៅរកទិសដៅមុខបន្តិច ដោយអ្នកមានទ្រព្យសម្បត្តិខ្លះនៅទីប្រជុំជន បានបញ្ជូនកូនអោយទៅរៀននៅសាលាបារាំង តែនៅមជ្ឈដ្ឋានខ្លះ សុំអនុញ្ញាតអោយកូនបានបួសមួយវស្សា « ៣ ខែ » នៅមហាវិស្សមកាល ដើម្បីអោយបានសងគុណឪពុកម្ដាយ ។ ជីតា ជីដូនខ្លះ មិនអោយចៅទៅរៀនភាសាបារាំងដោយខ្លាចបារាំងចាប់ធ្វើទាហានទៅច្បាំង និងខានបានបួសសងគុណមាតាបិតា ។

គោលបំណងដែលអោយទៅរៀននៅសាលាបារាំងនៅពេលនោះ គឺចង់ធ្វើអ្នករាជការបានប្រាក់បៀវត្ស និងមានឋានៈខ្ពស់ជាងឪពុកម្ដាយតែប៉ុណ្ណោះ ។ គេមិនគិតដល់រឿងការពារជាតិ កសាងជាតិអ្វីឡើយ ព្រោះស្នេហាជាតិនៅពេលនោះ នាំអោយវិនាសខ្លួន ។ គេសប្បាយនឹងទ្រព្យសម្បត្តិ បុណ្យសក្តិរបស់គេតែប៉ុណ្ណោះ ។

ឥលូវនេះរបបជិះជាន់អាណានិគមនិយមបារាំង និងរបបឃោរឃៅព្រៃផ្សៃបានកន្លងផុតទៅហើយ ។ ប្រទេសកម្ពុជា ក្រោយថ្ងៃ ៧ មករា ១៩៧៩ បានរៀបចំទិសដៅអប់រំទៅតាមលទ្ធិសង្គមនិយម ។ តែបច្ចុប្បន្នកាលនេះ សាលារៀនសង្គមនិយម គ្រួសង្គមនិយមត្រូវរលំរលាយ ហើយត្រូវទទួលយកទស្សនទានអប់រំថ្មីមួយទៀត ក្រោយពីឆ្នាំ ១៩៩៣ គឺការអប់រំក្នុងលទ្ធិប្រជាធិបតេយ្យសេរីនិយម ។ ដូច្នេះ តើគោលនយោបាយចង្អុលទិសដៅទៅយ៉ាងណា ។ តាមខ្ញុំយល់ គឺទៅតាមគន្លងប្រទេសប្រកាន់របបប្រជាធិបតេយ្យសេរី ដែលបាននិងកំពុងដើរសព្វថ្ងៃ ។

ជាសរុប ទស្សនទានអប់រំ ដែលបានសង្កេតឃើញមានបី ស្របទៅតាមសម័យកាល ។

១)- ទស្សនទានដែលយកអាទិទេព រឺ សាសនា ( Conception théocentrique ) ជាផ្ចិត រឺជាស្នូល ។ អ្វីៗទាំងអស់ទាក់ទិននឹងតួអង្គអាទិទេព ដោយមានបំណងចង់អោយអ្នកសិក្សាគោរពបូជា ចំពោះអាទិទេព ។

២)- ទស្សនទានដែលយកសង្គមមនុស្ស ( Conception sociocentrique ) ជាផ្ចិត រឺជាស្នូលដោយមានបំណងរៀបចំមនុស្ស ចូលរួមបំរើសង្គមអោយបានល្អតលាស់ល្អ ។

៣)- ទស្សនទានដែលយកមនុស្ស ( conception anthropocentrique ) ជាផ្ចិត រឺជាស្នូលដោយមានបំណងកសាងមនុស្ស អោយមានជីវភាពរស់នៅប្រកបដោយមនុស្សធម៌ពិតប្រាកដ « មានមេត្តាចេះជួយសង្គ្រោះគ្នា » ប្រកបដោយវិចារណញ្ញាណ និង មានសេរីភាព ។ ក្នុងជីវភាពបែបនេះ ទើបរកឃើញសុភមង្គល ។

ទស្សនទានទាំងបីខាងលើ នៅមានគេអនុវត្តសឹងតែគ្រប់ប្រទេសលើសកលលោកនៅឡើយ ។ ប៉ុន្តែនៅចុងសតវត្សទី២០នេះ ទំនោរអនុវត្តទស្សនទានទី៣ ទោរទន់មកខ្លាំងចំពោះការអប់រំមនុស្ស ។ ដូចខ្ញុំបានជំរាបខាងដើមហើយថា ពិភពលោកប្រាថ្នាចង់បានមនុស្សប្រកបដោយចិត្តធម៌ មានការយោគយល់គ្នា មានអធ្យាស្រ័យល្អ មានសិទ្ធិសេរីភាពគ្រប់គ្រាន់ មានសាមគ្គី និងមានការរាប់អានគ្នាជាបងជាប្អូន ។ ទស្សនទានអប់រំនេះ ជាឧត្តមគតិរបស់ទស្សនវិទូមួយចំនួនធំនាបច្ចុប្បន្នកាល ។ សហព័ន្ធអប់រំជាតិប្រទេសបារាំង បានលើកសំនូមពរបណ្ដុះបណ្ដាលមនុស្សម្នាក់ៗអោយមានលក្ខណៈសម្បត្តិបីប្រការ គឺ ៖

១- មនុស្សល្អ

២- ពលរដ្ឋល្អ

៣- ពលករល្អ

សំនួរសួរថា **តើមជ្ឈដ្ឋានទាំងបី គ្រួសារ សាលារៀន សហគមន៍ ត្រូវអប់រំកុមារដូចម្ដេច ដើម្បីអោយបានជាមនុស្សមានលក្ខណៈសម្បត្តិទាំងបីខាងលើ** ? ។ យើងខ្ញុំបានជំរាបរួចហើយក្នុងអត្ថបទ « តើអប់រំកុមារដូចម្ដេច » ? ។ សូមអានអត្ថបទឡើងវិញ ( ទស្សនាវដ្ដីលេខ ៣ ទំព័រ ១៦ )

គួរជ្រាបថា ទស្សនទានអប់រំប្រែប្រួលទៅតាមការវិវឌ្ឍន៍របស់សង្គម ។ ចិត្តវិទូយល់ឃើញថា គួរតែអប់រំមនុស្សទៅតាមបែបនេះ បែបនោះ ដើម្បីកែលំអសង្គម ។

សូមតាមដានពិនិត្យពិចារណាលើគោលដៅអប់រំជាតិ ( ខ្មែរ ) ដែលគណៈកម្មការកែលំអប្រព័ន្ធអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា បានកំនត់ក្នុងកម្មវិធីសិក្សាគោលសំរាប់បឋមសិក្សា ។ ខ្ញុំសុំដកស្រង់ទាំងស្រុងដូចខាងក្រោម ។

« ការអប់រំនៅប្រទេសកម្ពុជា មានគោលដៅកសាងមនុស្សពេញលេញ រីកចំរើនល្អគ្រប់ផ្នែកព្រមៗគ្នា ដោយមានតុល្យភាពរវាងប្រាជ្ញា ស្មារតី សញ្ចេតនា និងរូបរាងកាយ ។ គោលដៅនេះ ជាទាកសាងពលរដ្ឋថ្លៃថ្នូរ មានចំនេះដឹង បំនិនពិសោធន៍ សីលធម៌ អធ្យាស្រ័យ សហការ សាមគ្គីភាព ឯកភាពជាតិ មនសិការជាតិ ស្រលាញ់យុត្តិធម៌ គោរពច្បាប់ សិទ្ធិមនុស្ស យល់ដឹងថែរក្សាការពារបរិស្ថាន ចេះផ្សព្វផ្សាយ និងលើកកំពស់តំលៃវប្បធម៌ អរិយធម៌ជាតិ មានម្ចាស់ការទំនុកចិត្តលើខ្លួនឯង ចេះដោះស្រាយបញ្ហាក្នុងជីវភាពរស់នៅ ចេះច្នៃប្រឌិត ចេះធ្វើពលិកម្ម មានស្មារតីទទួលខុសត្រូវខ្ពស់ មានសមត្ថភាពកសាងសុខុមាលភាពគ្រួសារ ហើយអាចចូលរួមយ៉ាងសកម្មក្នុងការបង្រួបបង្រួមជាតិ ស្ដារ និងអភិវឌ្ឍន៍មាតុភូមិជាទីស្នេហា ដោយផ្អែកលើស្មារតីប្រជាធិបតេយ្យ សេរីពហុបក្ស ។ ក្នុងន័យនេះ ការអប់រំកម្ពុជាត្រូវជាទាបណ្ដុះបណ្ដាលពលករគ្រប់ជំនាញ កំរិតបឋម មធ្យម និង ឧត្ដម ដើម្បីបំពេញតំរូវការសង្គមជាតិ ហើយក៏ត្រូវជាទាកសាងជួរបញ្ញវន្តជំនាញៗ ក្នុងការគ្រប់គ្រងដឹកនាំ ក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រ សំរាប់អភិវឌ្ឍន៍ព្រះរាជាណាចក្រកម្ពុជា ក្រោមបាវចនាជាតិ សាសនា ព្រះមហាក្សត្រ »

ខ្ញុំលើកគោលដៅអប់រំមកជំរាបនៅទីនេះ ព្រោះអ្នកអប់រំ រឺ សង្គមខ្មែរចង់បានមនុស្សបែបនេះ ។ គេលើកគោលដៅ និងគោលការណ៍អប់រំ ដើម្បីអោយលោកគ្រូ អ្នកគ្រូ អនុវត្តអោយសំរេចគោលដៅ ។ រួមសេចក្ដីមក គោលដៅអប់រំគាត់តែងវែងអន្ទាយយ៉ាងណាក៏ដោយ ក៏នៅតែមានខ្លឹមសារបីសំខាន់ គឺមនុស្សល្អ ពលរដ្ឋល្អ ពលករល្អ ។ សព្វថ្ងៃនេះ ក្រសួងអប់រំ យុវជន និងកីឡា បានកំនត់គោលដៅបី ស្របទៅតាមគោលដៅបណ្ដុះបណ្ដាលសកល គោលដៅទាំងបីមានលំដាប់ថ្នាក់ដូចតទៅ ៖

- ចំនេះដឹង រឺ ពុទ្ធិ
- ចំនេះធ្វើ រឺ បំនិនប្រសប់
- ចរិយាធម៌ឥរិយាបថ អាកប្បកិរិយា

ដោយសីលធម៌សង្គមចេះតែស្រុតចុះនៅលើពិភពលោក ទស្សនាវិទូ ចិត្តវិទូ គរុកោសល្យវិទូ បានទឹកភ្នកចង់រៀបចំលំដាប់ថ្នាក់នៃគោលដៅអប់រំបញ្ច្រាស់ពីក្រោមឡើងលើវិញ ដោយចង់លើកតំកើងការអប់រំសីលធម៌អោយខ្ពស់ជាងការផ្ដល់ចំនេះដឹង និងបំនិនប្រសប់ ។ គោលដៅទាំងបីនេះ ត្រូវបានស្នើអោយរៀបដូចតទៅនេះ ។

១- ចរិយាធម៌ រឺ សីលធម៌ ( savoir - être - comportements )

២- បំនិនប្រសប់ ( Savoir - faire - compétences )

៣- ចំនេះដឹង (savoirs - connaissances )

គំនិតបំរែបំរួលនេះ ប្រទេសជប៉ុនព្រមជាមួយប្រទេសមួយចំនួនទៀត បានបញ្ចេញមតិយោបល់កាលពីឆ្នាំ ១៩៧៤ ក្នុងអង្គប្រជុំមួយរៀបចំដោយវិទ្យាស្ថានអង្គការយូណេស្កូ ដើម្បីការអប់រំ ( Institut de l'UNESCO pour l'éducation ) ។ ប៉ុន្តែមកទល់ពេលនេះ គំនិតកែប្រែនេះ នៅមិនទាន់បានសំរេចអនុវត្តទៅយ៉ាងណានោះនៅឡើយទេ ។ គំនិតនេះ ត្រូវបានពង្រឹងនៅគ្រប់សិក្ខាសាលាអន្តរជាតិ ជាពិសេសនៅឆ្នាំ ១៩៧៨ ។ នៅចុងសតវត្សទី ២០ នេះ ( ១៩៩៦ ) គណៈកម្មការអន្តរជាតិនៃអង្គការយូណេស្កូ ដែលមានសមាជិក ១៥ នាក់ ដឹកនាំដោយលោកប្រធាន ហ្សាគដឺល័រ ( Jacques Delors ) បានសិក្សាពីការអប់រំសតវត្សទី ២១ [១] ។ គណៈកម្មការនេះ បានកំនត់គោលដៅមួយបន្ថែមទៀត ទៅលើគោលដៅទាំងបី ដែលមានរួចមកហើយ ហើយរៀបចំលំដាប់ថ្នាក់ដូចតទៅ ៖

| | |
|---|---|
| រៀនអោយបានចេះដឹង | apprendre à connaitre |
| រៀនធ្វើ | apprendre à faire |
| រៀនរស់អោយស្របតាមសីលធម៌ | apprendre à être |
| រៀនយល់អ្នកដទៃ | apprendre à comprendre l'autre |

ជាការសន្និដ្ឋាន ទិសដៅអប់រំកំនត់ឡើងទៅតាមទស្សនទាននៃការអប់រំ ដែលវិវឌ្ឍទៅតាមសង្គមមនុស្សដូចបានជំរាបជាហូរហែមកហើយ ដោយចិត្តរិទ្ធយល់ឃើញថា សង្គមមនុស្សមានការអភិវឌ្ឍ រីកចំរើនដោយសារមនុស្ស ។

**យ៉ង់ ធី**

## សំដីញុះញង់ ជាអន្លង់បំបែកសាមគ្គី

(១) . Le monde de l'Education - mars 1996 page 6

# ដំនាក់នៃការអប់រំ និង ដំបូន្មានចំពោះឪពុកម្ដាយ និង អ្នកអប់រំ
# Les étapes de l' éducation et les conseils aux parents et aux éducateurs

ខ្ញុំលើកពីដំនាក់ ( étapes ) នៃការអប់រំមកជំរាប ដើម្បីបំពេញបន្ថែមលើការងារអប់រំ ព្រោះការអប់រំទាមទារការយល់ដឹងពីការលូតលាស់ទាំងខាងសរីរាង្គ ទាំងខាងស្មារតីរបស់កុមារ ។

ចិត្តគរុវិទូចែកដំនាក់អប់រំជាបីចំនែកស្របទៅតាមអាយុ គឺគិតពីអាយុ ១ ឆ្នាំ ដល់ ២០ ឆ្នាំ ។

**ក - កុមារភាពចែកជាបីកាល :**

- ទី១ ចាប់ពីកំនើតដល់អាយុ ៣ ឆ្នាំ
- ទី២ ចាប់ពីអាយុ ៣ ឆ្នាំ ដល់អាយុ ៧ ឆ្នាំ
- ទី៣ ចាប់ពីអាយុ ៧ ឆ្នាំ ដល់អាយុ ១១ រឺ ១២ ឆ្នាំ

**ខ - ភាពជំទង់ចែកជាបីកាល :**

- ទី១ ចាប់ពីអាយុ ១២ ឆ្នាំ ដល់អាយុ ១៤ ឆ្នាំ
- ទី២ ចាប់ពីអាយុ ១៥ ឆ្នាំ ដល់អាយុ ១៧ ឆ្នាំ
- ទី៣ ចាប់ពីអាយុ ១៨ ឆ្នាំ ដល់អាយុ ២០ ឆ្នាំ

**គ - ភាពពេញវ័យ** គឺគិតពីក្រោយពេលពេញជំទង់ រហូតដល់ការលូតលាស់ខាងសរីរាង្គ និងខាងស្មារតី ត្រូវបានចប់ ( développement psycho-organique terminé ) ។

ការបែងចែកនេះ ខ្ញុំបានបែងចែកទៅតាមឯកសាររបស់ចិត្តវិទូបរទេស ។ ចំនែកការលូតលាស់សរីរាង្គ បញ្ញា និងចិត្តនៃកុមារា កុមារីខ្មែរ មិនទាន់មានចិត្តវិទូខ្មែរណាម្នាក់ បញ្ចេញនូវស្នាដៃស្រាវជ្រាវនៅឡើយទេ ។ ទាំងគេទាំងខ្ញុំ នាំគ្នាថាតាមទ្រឹស្ដីដែលបានរៀនកាលនៅក្នុងសាលាគរុកោសល្យ ។ ខ្ញុំមានមតិដូចនេះ ដោយខ្ញុំយល់ថា ការលូតលាស់កុមារកម្ពុជា ប្រហែលជាខុសគ្នាខ្លះពីកុមារអឺរ៉ុប ព្រោះធាតុអាកាស ទីតាំងនៅប្រទេសយើង និងម្ហូបអាហារខុសគ្នានឹងធាតុអាកាស ទីតាំងនៅ និង ម្ហូបអាហារអឺរ៉ុប ។

ខ្ញុំលើកដំនាក់អប់រំមកជំរាប គឺចង់អោយឪពុកម្ដាយ លោកគ្រូ - អ្នកគ្រូ តាមដានការវិវត្តនៃការលូតលាស់របស់កុមារកម្ពុជា ដើម្បីជាសញ្ញានៃការអប់រំទៅតាមវ័យ ។ ដូច្នេះ ជាបន្តបន្ទាប់ ខ្ញុំសូមលើកតាមលំដាប់លំដោយនៃការលូតលាស់របស់កុមារ តាមការបែងចែកខាងលើ ។ តែមុននឹងសិក្សាពីដំនាក់អប់រំនីមួយៗ ខ្ញុំសូមជំរាបថា តាមការស្រាវជ្រាវថ្មីៗនេះ ចិត្តវិទូបានអោយដឹងថា ការអប់រំកូនចៅ មិនមែនចាប់ផ្ដើមតាំងពីទារកមកនោះទេ គឺចាប់តាំងពីទារកនៅក្នុងផ្ទៃម្ដាយ ។

ទារកនៅក្នុងផ្ទៃម្ដាយ បានដឹងអ្វីៗទាំងអស់នៅខាងក្រៅ ។ ឧទាហរណ៍ ៖ ម្ដាយទទួលទានម្ហូបអាហារជូរចត់ល្វីង ហឹរជាដើម ។ ម្ដាយកើតទុក្ខព្រួយ រញ៉ាំរញ៉ូវ ឡូឡា មួម៉ៅ ឈ្លោះប្រកែក រឺ ផ្ទុយទៅវិញ សប្បាយរីករាយ ទឹកមុខស្រស់ពព្រាយ សុខភាពបរិបូរ បង្កអោយទារកញាប់ញ័រដើតតាមអត្តចរិតម្ដាយតាមមនោសញ្ចេតនា ។ ម្យ៉ាងទៀតតាមតំនពូជ អ្នកអប់រំព្រមទាំងអ្នកវិទ្យាសាស្ត្របានអោយដឹងថា ទោះតិចក្ដី ច្រើនក្ដី ទារកនាំមកពីកំនើតនូវភិនភាគ រឺ អត្តចរិតរបស់ឪពុក រឺ ម្ដាយ ។ គេតែងពោលថា កូននេះកាត់ទៅឪពុក រឺ កាត់ទៅម្ដាយ ។ ក្រោមឥទ្ធិពលនៃតំនពូជ និងឥទ្ធិពលនៃមជ្ឈដ្ឋានគ្រួសារ សាលារៀន និង សង្គម កុមារម្នាក់ៗមានបុគ្គលិកលក្ខណៈប្លែកៗគ្នា ។ អត្តចរិត រឺ អាកប្បកិរិយាប្លែកៗគ្នា អាចប្រែប្រួលបានដោយសារការអប់រំ ថែបំប៉នរបស់ឪពុកម្ដាយ លោកគ្រូ អ្នកគ្រូ និងសង្គម ។

ខ្មែរយើងច្រើនពោលថា « ផ្លែឈើមិនដែលជ្រុះឆ្ងាយពីគល់ » ពាក្យនេះត្រូវខ្លះ ខុសខ្លះ ។ ផ្លែឈើអាចជ្រុះឆ្ងាយពីគល់បាន ។ ខ្ញុំសូមលើកយករឿងមួយ ដែលលោក **អូសស្ទេរីត** ( Osterrieth ) បាននិទានក្នុងសៀវភៅរបស់លោកមកជំរាបដូចតទៅ ៖

កុមារីម្នាក់អាយុ ២ ឆ្នាំ ត្រូវបានបោះបង់ចោលដោយកុលសម្ព័ន្ធមួយមានអារ្យធម៌អន់ថយបំផុតនៅទ្វីបអាមេរិចខាងត្បូង ។ កុមារីនេះ ត្រូវបានរើសយកទៅចិញ្ចឹមដោយជាតិពន្ធុវិទូម្នាក់ ( Ethnographe ) ក្នុងលក្ខណៈប្រសើរបំផុត ។ ពេលអាយុបាន ២៧ ឆ្នាំ យុវនារីនេះ ចេះនិយាយបីភាសា ហើយបានរៀនចប់សាកលវិទ្យាល័យ [១] ។

I- កុមារភាព « សរុបពីកំនើតរហូតដល់អាយុ ១២ ឆ្នាំ » ចាប់ពីបានកាត់ទងសុក្ករួចមក ទារកត្រូវបានមករស់នៅក្នុងពិភពថ្មីមួយ ( milieu aérien ) ខុសគ្នាពីកាលនៅក្នុងទងសុកមាតា ( milieu placentaire ) ។ ភារកិច្ចអប់រំត្រូវមានចាប់ពីពេលនេះតទៅ ។ ក្នុងកុមារភាពកាលទី១ ( première enfance ) គេចែកជាពីរដំនាក់ ( deux phases ) នៃការលូតលាស់ ។

ដំនាក់ទី១ មានរយៈពេល ១២ ខែ គឺជាដំនាក់ចាប់ផ្ដើមពន្លកនៃភាពរួស គឺភាពងាយនឹងចាប់អារម្មណ៍ខាងផ្លូវចិត្ត រឺគឺជាដំនាក់មិនទាន់ចេះនិយាយ ។

ដំនាក់ទី២ មានរយៈកាល ២ ឆ្នាំ គឺឆ្នាំទី២ និងទី៣ ។ ក្នុងដំនាក់ទី២ នេះ ទារកចេះដើរ និងចេះនិយាយ ។

ក្នុងកុមារភាពកាលទី១ នេះ ទារកត្រូវការការថ្នាក់ថ្នមពីមាតា ។ កុមារត្រូវការរឹមដោះ និងកំរើក ដៃជើង ។ នៅខែដំបូង វាគេងច្រើន រឹមក៏ច្រើន ។ ពេលរឹមភ្នែក វាបើកភ្នែកមើលពន្លឺ រឺ មើលនេះមើលនោះនៅជុំវិញខ្លួនវា ។ ជួនកាលវាញញឹមលេងតែម្នាក់ឯង រឺនៅពេលណាវាឃើញច្បាស់ហើយវាឃើញម្ដាយវាញញឹមរកវាមុនគេបង្អស់ វាញញឹមតបវិញ ។

វេទយិតភាព ( sensibilité ) នៃពន្លឺ និងសំលេងកាន់តែឃើញ និងលឺបានល្អ ។ ចាប់ពីខែទី ៤ ទារកចេះបញ្ចេញសំលេង កកែកករ ។ កុមារចេះភ័យ ចេះខឹង និងចេះសប្បាយរីករាយ លេងសើច ។ វិញ្ញាណទាំងប្រាំបានលូតលាស់ ។ កុមារចង់ឃើញ ចង់ចាប់ពាល់និងចង់ធ្វើត្រាប់ ។ ដំបូងកុមារចេះក្រឡាប់ ចេះលូន ចេះវារ ចេះអង្គុយ ចេះតោងឈរ ចេះដើរបានទៅតាមការលូតលាស់យឺត រឺ រាប់ ។

ការលូតលាស់ធំធាត់របស់កុមារ ផ្នែករាងកាយ និង បញ្ញា ទាមទារការប៉ិនប្រសប់ និង យកចិត្តទុកដាក់របស់មាតា ( អនាម័យ ចំនីអាហារស្អាត មានជីវជាតិគ្រប់គ្រាន់ ដំនេកពេញលេញស្កប់ស្កល់ ) ។

(១) Introduction à la psychologie de l'enfant page 26

កុមារអាយុមួយខួប ដែលបានទទួលការថែទាំល្អ បានឆ្លងជំនាក់ទី១ ដោយជោគជ័យ ពោលគឺបានយល់ពីអ្វីដែលគេនិយាយទៅរកខ្លួន ។ ម្ដាយរីករាយណាស់ សរសើរពីកូនខ្លួនមិនដាច់ពីមាត់ប្រាប់គេឯងថា កូននេះដឹងសព្វដឹងគ្រប់ តែគ្រាន់តែឆ្លើយតបមកវិញមិនបាន ។

នៅពេលនេះដែរ កូនត្រូវបានផ្ដាច់ដោះ ។ ការលែងអោយកូនបៅ គឺជាការមួយដែលម្ដាយត្រូវរៀបចំអោយបានស្រួលល្អ រកឱកាសល្អ មិនកាត់ផ្ដាច់ដាច់ណាត់តែម្ដង ។ ពេលនោះ គេឃើញកូនង៉េតមុខស្រងូត ។ ម្ដាយច្រើនយកអ្វីមកលាបចុងដោះបញ្ឆោតថា ល្វីងណាស់ ស្អុយណាស់ ។ បាតុភាពមួយដែលគួរអានិត គឺនៅពេលម្ដាយមានគភ៌ ។ ការផ្ដាច់ដោះមិនល្អ ជាគុណវិបត្តិផ្លូវចិត្តនៅពេលកុមារកំពុងលូតលាស់ ។ ប្រការនេះ បង្កើតជាបញ្ហាដល់អ្នកអប់រំ ។ ការរៀនដើរចេះតែបន្តទៅមុខ ។ គេក្រោក គេអង្គុយទៅវិញ គេតោង ។ តាមការសង្កេត កុមារីឆាប់ចេះដើរមុនកុមារា ។ នៅពេលរៀនដើរនេះ ឪពុកម្ដាយមិនត្រូវបង្ខំកូនទេ ព្រោះនាំអោយជើងកុមារកោងទៅអនាគត ។ ចាប់ពីឆ្នាំទី២ កូនចេះនិយាយ ។ មុនដំបូង គេចេះតែពាក្យមួយម៉ាត់ៗ រួចហើយគេចេះផ្គុំបានពីរបីម៉ាត់ ។ ឧទាហរណ៍ : ទៅផ្សារទិញនំ ។ ល ។ ការដែលចេះនិយាយនេះ នាំមកនូវមនោសញ្ចេតនាខុសពីមុន គឺគេជាប់ចិត្តទៅនឹងអ្វីមួយ រឺគេស្អប់អ្វីមួយ ។ គេចង់អោយតែម្ដាយពរ ។ គេចង់លេងជាមួយបងប្អូន រឺ កុមារដទៃ ។ កុមារចូលចិត្តអោយគេនិយាយរកខ្លួន ។ កុមារមិនចង់អោយគេក្រញិចក្រញិលខ្លួនទេ ។ ប៉ុន្តែ កុមារចង់អោយគេនាំខ្លួនលេងប្រលែង រឺលេងជាមួយក្មេងៗដូចគ្នា ។

នៅជំនាក់ទី១ នេះ កុមារចេះញ៉ាំបាយហើយ ។ កុមារមិនចង់អោយម្ដាយបញ្ចុកខ្លួនទេ ។ កុមារចង់ធ្វើដូចគេដូចឯង គឺកាន់ស្លាបព្រាខ្លួនឯង ។ នៅគ្រប់ពេល ឪពុកម្ដាយគួរទំលាប់កូនអោយកាន់អ្វីទាំងអស់នៅដៃស្ដាំ ព្រោះកុមារមិនទាន់មានទំលាប់អ្វីជាជាប់លាប់ទេ ។ គួរធ្វើដូចខ្ញុំជំរាបនេះ ទើបប្រសើរទៅអនាគត ពោលគឺនៅពេលកុមារពេញរូបរាង ។ តែបើសង្កេតឃើញថា កូនមិនព្រមតាមទេនោះ សូមកុំបង្ខំឡើយ ព្រោះជាទំនោរពីកំណើត ។ ម្យ៉ាងទៀត ដោយនៅមិនទាន់ចេះកាន់ស្លាបព្រាល្អ កុមារតែងតែធ្វើអោយកំពប់ខ្លះនាំអោយមិនស្អាត ។ តែគួរអធ្យាស្រ័យ ព្រោះកុមារនឹងមានទំលាប់ល្អនៅពេលខាងមុខ ។

ក្នុងរយៈពេលកុមាររៀននិយាយ គួរតែម្ដាយនាំកូននិយាយអោយបានច្បាស់ៗ ទៅតាមសំលេងតួអក្សរ ។ បញ្ហាទាំងនេះ តាមខ្ញុំសង្កេត គឺអាស្រ័យទៅតាមតំបន់ ។ ស្រុកណា ខេត្តណានិយាយត្រឹមត្រូវតាមអក្សរយើងស្ដាប់ទៅគួរអោយចង់ស្ដាប់ ។ នៅតំបន់ខ្លះ គឺខុសឆ្ងាយពីសំលេងអក្សរ ។ ដូចនេះ បញ្ហាភាសានិយាយមិនបានដូចបំនងដែលយើងចង់បាននោះទេ ។ ប៉ុន្តែ កាលណាកុមារចូលមករៀននៅសាលា ទំលាប់និយាយខុស គឺអាចនឹងកែបានល្អវិញ ប្រសិនបើគ្រូយកចិត្តទុកដាក់ត្រឹមត្រូវតាមក្បួនគរុកោសល្យ ។ នៅជំនាក់ទី១នេះដែរ គួរម្ដាយចៀសវាងអោយបានជាដាច់ខាត កុំបង្រៀនកូនអោយចេះជេរ ដើម្បីសើចលេងសប្បាយនៅពេលកូនចេះពាក្យមួយម៉ាត់ៗ ហើយមិនទាន់ច្បាស់ ។ ម្ដាយនាំអោយចេះជេរនេរណា ដែលមកក្រញិចក្រញិលកុមារ ដែលនាំអោយវាឃ្មំ ។ ម្យ៉ាងទៀត កុំបញ្ឆោតកុមារ កុំបំភ័យ កុំកំញើញ កុំសំលុត ដោយសំដីខ្លាំងៗ ។

នៅរយៈពេលនេះដែរ ប្រសិនបើម្ដាយមានកូនង៉េតថ្មីមកទៀតនោះ កូនមុនមុខជាមានទឹកមុខមិនស្រស់ ដោយឃើញម្ដាយថ្នាក់ថ្នមប្អូនប្រុស រឺប្អូនស្រីថ្មី ។ ការច្រណែននេះ វាជាអត្តចរិតធម្មតារបស់កុមារ ។ ឪពុកម្ដាយ ត្រូវមានភារកិច្ចយកចិត្តទុកដាក់ចំពោះកូនមុន កុំព្រងើយកន្តើយអោយសោះ ។

ជាសរុប តាមចិត្តគរុកោសល្យវិទ្យា កុមារា កុមារី ដែលមានអាយុ ២ រឺ ៣ ឆ្នាំ មានការលូតលាស់ល្អប្រពៃគួរជាទីមោទនៈរបស់ឪពុកម្ដាយ ព្រមទាំងជីដូនជីតា ។ កុមារចេះនិយាយកាន់តែច្បាស់ ចេះដើរ រត់ ។ មិនតែប៉ុណ្ណោះ

សមត្ថភាព បញ្ញា ( faculté intellectuelle ) « ចេះសួរ ចេះធ្វើគ្រាប់ » ឥទ្ធិយារម្មណ៍គ្រប់បែបយ៉ាង « ខឹង សប្បាយ ឯរ » បានចេញជាពន្លកមកអោយយើងឃើញ ។ ចរិតគំនូជក៏ឃើញខ្លះដែរ ។ កុមារខ្លះរីករាយ ខ្លះតក់ម៉ក់មិនសូវនិយាយស្តី ។ ល ។ ឪពុកម្តាយត្រូវចេះបង្កើតមជ្ឈដ្ឋានគ្រួសារអោយបានស្ងប់ មានព្រហ្មវិហារធម៌ចំពោះកូនដែលជាគន្លឹះអោយកូនមានលំនឹងល្អ ។ ការងារអប់រំកូនចៅ ជាការងារស្មុគ្រស្មាញ ទាមទារអំនត់ ។ យើងឃើញក្នុងគ្រួសារនីមួយៗ រឺ ក្នុងសង្គមខ្មែរយើងទាំងមូលមាន ៖

១- កូនទោលនៅម្នាក់ឯងជាមួយឪពុកម្តាយ ។ តើវានឹងមានអាកប្បកិរិយាយ៉ាងណាទៅអនាគត ? តើឪពុកម្តាយអប់រំវាយ៉ាងណា ដើម្បីអោយចេះរស់នៅក្នុងសង្គម ?

២- កូនដែលឪពុកម្តាយទំរើសខ្លាំង និងកូនដែលឪពុកម្តាយមិនសូវរវល់ជាមួយវា ។

៣- កូនដែលឪពុកម្តាយសំលុត វាយ ញ៉រវន្ទត់នៅពេលមានកំហុសអ្វីមួយ ។

ឃើញដូច្នេះ តើឥរិយាបថឪពុកម្តាយត្រូវប្រកាន់បែបណា ? ខាងលើនេះ គឺជាកូនមានឪពុកម្តាយថែរក្សា ។ ចុះកូនត្រូវគេបោះបង់ចោល កូនកំព្រា កូនមានរាងកាយ និងបញ្ញាមិនដូចគេឯង ខ្វះវិញ្ញាណណាមួយ ។

បញ្ហានេះ ខ្ញុំលើកឡើងដើម្បីទាក់ទាញអារម្មណ៍អ្នកអប់រំដើម្បីជួយពិចារណា ? ខ្ញុំសូមបន្តភ្ជាប់នៅរឿងអាយុសិស្ស ដែលចាប់កំនើតរហូតដល់អាយុ ៣ ឆ្នាំ ហើយដែលត្រូវនៅក្នុងបន្ទុកអប់រំរបស់គ្រួសារ ។ ចាប់ពី ២ ឆ្នាំ ឡើងទៅ ម្តាយខ្លះជាអ្នករដ្ឋការ ត្រូវបង្ខំចិត្តយកកូនទៅផ្ញើនៅទារកដ្ឋាន ប្រសិនបើគ្មានជីដូន ជីតានៅផ្ទះទេ ។ រីឯកូនអ្នកនៅស្រុកស្រែចំការ ជួនការទុកអោយបងប្រុស រឺ ស្រី នៅចាំផ្ទះ និងមើលប្អូនផង ។ ម្តាយរវល់ទៅដកស្ទូង រឺ ច្រូត ។ ជួនកាល គេបររទេះដាក់កូនទៅជាមួយផង ។ គេចងអង្រឹងក្រោមរទេះ រឺ ក្រោមដើមឈើទុកអោយកូនតូចមួយអង្គុយយោល ។ លុះកូនអាយុ ៣ ឆ្នាំ ដល់ ៥ ឆ្នាំ គួរឪពុកម្តាយយកទៅដាក់សាលាមត្តេយ្យ ព្រោះសព្វថ្ងៃនេះ ម្តាយច្រើនតែអ្នករដ្ឋការដូចប្តីដែរ ព្រោះសេដ្ឋកិច្ចគ្រួសារវាចោទខ្លាំង រីមួយម្តាយមានភារកិច្ចទៅរកស៊ីលក់ដូរតិច រឺ ច្រើនទៅតាមទុនរបស់ខ្លួន ។ ការផ្ញើកូនទៅសាលាមត្តេយ្យនៅទីក្រុង វាមិនចោទជាបញ្ហាទេ ។ ប្រការនេះ ចោទតែនៅស្រុកស្រែចំការដែលមិនមានសាលាមត្តេយ្យ រីមានដែរ តែនៅឆ្ងាយពីផ្ទះសំបែងរបស់ខ្លួន ។ ជួនកាល ឪពុកម្តាយត្រូវបង់វិភាគទានខ្លះជាស្រូវ ជាប្រាក់ ជួយឧបត្ថម្ភជីវភាពអ្នកគ្រូ ។ ការផ្ញើកូនប្រុសស្រីនៅសាលាមត្តេយ្យ ជាទង្វើមួយដ៏ល្អប្រសើរព្រោះ ៖

- ទី១ : បន្ធូរបន្ទុកម្តាយ
- ទី២ : កូនបានរស់នៅជាមួយកុមារដទៃទៀត និងបានពង្រីកគំនិតស្រលាញ់គ្នា រួសរាយ ញញឹមញញែមរកគ្នា
- ទី៣ : កូនមានការអប់រំល្អពីអ្នកគ្រូ ដែលមានចំនេះដឹងគ្រប់គ្រាន់ខាងផ្នែកអប់រំ ។ ប៉ុន្តែប្រសិនបើខ្វះសំភារៈឧបត្ថម្ភ រីមនសិការវិជ្ជាជីវៈ ការអប់រំក៏មិនបានផលល្អដែរ ។ ក្នុងអំលុងពេលផ្ញើនេះ ម្តាយត្រូវសហការយ៉ាងជិតស្និទ្ធជាមួយអ្នកគ្រូ ដើម្បីជួយកែលំអកូនអោយបានល្អ ។

សាលាមត្តេយ្យ រឺ ហៅម៉្យាងទៀតថា សួនកុមារមានទិសដៅអប់រំដូចគ្នា ។ មុននឹងជំរាបពីទិសដៅ ខ្ញុំសូមលើកយកពាក្យសួនកុមារមកបកស្រាយជូនជ្រាបសិន ព្រោះមានខ្លះយល់ច្រលំថា កន្លែងនេះ ជាសួនសំរាប់អោយកុមារាកុមារីលេង ដោយឃើញមានទោងសំរាប់អោយក្មេងយោល រីឧបករណ៍សំរាប់អោយកុមារលេង ។ ការយល់នេះមិនសមទេ ។ ពាក្យសួនប្រែថា ដីមានដាំដើមឈើផ្សេងៗជាលំអ ។ ជាមួយពាក្យនេះ កើតជាពាក្យសួនច្បារ សួនផ្កា

សួនសត្វ សួនឧទ្យានជាដើម ។ លោកហ្វ្រឺបែល (Fröebel) « ១៧៨២ - ១៨៥២ » គរុវិទូជាតិអាល្លឺម៉ង់បានបង្កើតក្នុងឆ្នាំ ១៨៣៧ នូវសួនកុមារ (jardin d'enfants) ហើយថែមទាំងបង្កើតសំភារៈសំរាប់អោយកុមារលេងទៀត ។ គាត់យល់ថា កូនឈើ រឺកូនផ្កាដែលដកយកពីថ្នាល រឺរងទៅដាំក្នុងសួននៅតូចណាស់ ត្រូវអ្នករក្សាសួនយកចិត្តទុកដាក់ថែទាំណាស់ ទើបកូនផ្កា រឺកូនឈើនេះដុះបានល្អ ។ រីឯកុមារា - កុមារី ដែលផ្តាច់ចេញពី( មជ្ឈដ្ឋានគ្រួសារ (milieu familial) ត្រូវបានប្រដូចទៅនឹងកូនឈើតូចដកពីថ្នាល ហើយយកទៅដាំក្នុងសួននោះដែរ ។

រីឯមត្តេយ្យសាលាមានន័យថា សាលារបស់មាតា រឺ សាលាទទួលថែរក្សាកូនជំនួសម្តាយបង្កើត ។

ទិសដៅអប់រំនៃសាលានេះ គឺបន្តការថែទាំកុមារមកពីទារកដ្ឋាន រឺមកពីគ្រួសារ ដើម្បីរំដោះមាតាជាពលករ ។ មិនតែប៉ុណ្ណោះ សាលានេះមានភារៈ ៖

១- ធ្វើអោយរាងកាយបានលូតលាស់ល្អ

២- ធ្វើការអប់រំវិញ្ញាណ « ជាពិសេស ចក្ខុវិញ្ញាណ សោតវិញ្ញាណ កាយវិញ្ញាណ »

៣- ធ្វើអោយញាណិច្ឆតាខាងបញ្ញា (curiosités intellectuelles) បានដុះដាលឡើង និងធ្វើការបណ្តុះបណ្តាលអោយមានទំលាប់ល្អខាងចរិយា ដើម្បីត្រៀមចូលសាលាបឋមសិក្សា ។ ឪពុកម្តាយដែលយកកូនទៅអោយរៀននៅសាលាមត្តេយ្យ គួរតែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយអ្នកគ្រូ ដើម្បីប្រាប់គ្នាទៅវិញទៅមក នូវចរិតលេចឡើងក្នុងពេលនៅផ្ទះ និងនៅសាលា ។ រូបមន្តដែលចិត្ត - គរុកោសល្យវិទូបានលើកមកប្រាប់ឪពុកម្តាយ និងលោកគ្រូ អ្នកគ្រូនៅសាលាគ្រប់ជាន់ថ្នាក់ ហើយគេទទួលស្គាល់ថាមានប្រសិទ្ធិភាពនោះ គឺគំរូល្អ និងសំដីល្អ ដើម្បីបំបាត់វិបត្តិភាពរឹងនៃកុមារអាយុ ៣ ឆ្នាំ (crise d' opposition) ។

យោលទៅតាមការសង្កេតរបស់ក្រសួងអប់រំ « កុមារដែលបានឆ្លងកាត់សាលាមត្តេយ្យ រៀនសូត្របានល្អជាងកុមារដែលមិនបានឆ្លងកាត់សាលាមត្តេយ្យ ។ ឧទាហរណ៍ : តាមការសាកល្បងនៅសាលាបឋមសិក្សា « ចតុមុខ » កាលពីឆ្នាំសិក្សា ១៩៨៧ - ៨៨ បង្ហាញអោយឃើញថា កុមារចំនួន ៩៦,២០ ភាគរយ ដែលបានឆ្លងកាត់សាលាមត្តេយ្យបានឡើងថ្នាក់ពីទី១ ទៅទី ២ ។ ចំនែកកុមារឯទៀត បានឡើងថ្នាក់តែ ៥៦,៧០ ភាគរយប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ គួរឪពុកម្តាយយកកូនទៅផ្ញើអោយរៀននៅសាលាមត្តេយ្យ ដើម្បីនឹងបានទទួលផលប្រយោជន៍ទាំងពីរផ្នែក គឺ ៖

១- ចំពោះម្តាយផ្ទាល់

២- កូនលូតលាស់ល្អទាំងរាងកាយ និង បញ្ញា

ចាប់ពីអាយុ ៦ ឆ្នាំ កុមារត្រូវទៅរៀននៅសាលាបឋមសិក្សា រហូតដល់អាយុ ១១ ឆ្នាំ និងនៅអនុវិទ្យាល័យ និងវិទ្យាល័យតទៅទៀត រហូតដល់អាយុប្រហែល ១៦ រឺ ១៧ ឆ្នាំ ។ នេះជាសិស្សធម្មតា ។

នៅក្នុងរយៈពេលសិក្សានេះ កុមារា កុមារី នៅបឋមសិក្សា មានការលូតលាស់ខាងសតិបញ្ញា ខាងឆន្ទៈ ខាងរូបារម្មណ៍ល្មមនឹងចាប់បានចំនេះដឹង ដែលលោកគ្រូ អ្នកគ្រូផ្តល់អោយ ដូចជាការរៀនអាន រៀនសរសេរ រៀនទព្វន្តជាដើម ។

ខ្ញុំសូមជំរាបបន្ថែមថា នៅបឋមសិក្សា នាបវេសនកាលម្តងៗ គេលឺស្ងួរក្មេងយំទ្រហឹង លាយឡំនឹងសំលេងខៀវខ្វារនៃកុមារា កុមារី ។ សំលេងយំនោះ គឺជាសិស្សថ្មីដែលមិនចង់ផ្តាច់ដៃចេញពីម្តាយ ទោះជាម្តាយអង្វរករយ៉ាងណាក៏ដោយ ។ ជួនកាល វាសុខចិត្តចូល តែអោយម្តាយឈរចាំនៅមុខសាលា ។ នេះជាពេលវេលាដ៏ពិបាក ព្រោះមជ្ឈដ្ឋានថ្មីនេះ ជាពិភពមួយប្លែកចំពោះកុមារ ។ លោកគ្រូ រឺអ្នកគ្រូក៏កុមារមិនដែលឃើញ ។ កុមារឯទៀត ក៏កុមារនេះមិនដែលឃើញដែរ ។ នេះជាការកាត់ផ្តាច់ខាងផ្លូវចិត្ត (sevrage psychologique) ។ ចំពោះកុមារា កុមារី ដែលបានទៅរៀននៅសាលាមត្តេយ្យ វាមិនជាការពិបាកទេ ព្រោះវាធ្លាប់រស់នៅជាមួយកុមារដទៃរួចហើយ ។ ប៉ុន្តែ សិស្សថ្មីយើងនេះ កន្លងបាន ២ រឺ ៣ សប្តាហ៍ក្រោយមក ក៏សប្បាយរីករាយនឹងទៅរៀន ព្រោះគេមានស្គាល់សិស្សដែលអង្គុយជិត ស្គាល់លោកគ្រូ រឺអ្នកគ្រូប្រចាំថ្នាក់ ។

កុមារចូលចិត្តលេងជាក្រុមជាមួយសិស្សដទៃ ។ នេះជាសង្គមកម្ម (socialisation) របស់កុមារា កុមារី ។ ការចូលទៅក្នុងមជ្ឈដ្ឋានថ្មីនេះ នាំអោយមជ្ឈត្តនិយមរបស់កុមារ (égocentrisme) ថយចុះបន្តិចម្តងៗស្របនឹងអាយុពី ៧ ឆ្នាំឡើងទៅ ។ កាលនៅសាលាមត្តេយ្យ គំនិតមជ្ឈត្តិកៈនៅខ្លាំងនៅឡើយ ។ ក្នុងអំឡុងកុមារភាពថ្នាក់ទី ៣ នេះ គឺក្នុងចន្លោះពី ៦ ដល់ ១២ រឺដល់ ១៤ ឆ្នាំ កូនមានចរិតមួយដែលគ្រូ និងឪពុកម្តាយពេញចិត្ត ព្រោះកូននេះទទួលនូវដំបូន្មានដ៏ល្អរបស់ឪពុកម្តាយ និងលោកគ្រូ - អ្នកគ្រូ ។ គេគោរពគ្រូ និង ឪពុកម្តាយ ។ ឱកាសនេះហើយ ដែលឪពុកម្តាយ គ្រូបាអាចារ្យណែនាំអោយមានទំលាប់ល្អ ។ ទំលាប់ កាលណាបានជិតជាប់ហើយ វាមិនរលុបរលាយទៅងាយៗទេ ។ ម្យ៉ាងទៀត បឋមសម្បទាបានលេចឡើងអោយគ្រូ និងឪពុកម្តាយឃើញ ។ គេឃើញកូនចូលចិត្តលេងនេះ លេងនោះ ។ ឧទាហរណ៍ : កុមារកាន់ញញួរវាយដែកគោល ចូលចិត្តរៀនច្រៀង រៀនរាំ ។ កុមារា កុមារីខ្លះ ត្រូវបានជ្រើសរើសដោយអ្នកគ្រូអោយច្រៀងជាក្រុម រាំរបាំផ្សេងៗជាដើម ។

ទន្ទឹមនេះដែរ គេសប្បាយនឹងជំរាបឪពុកម្តាយគេពីការរៀនសូត្រ ។ គេនិយាយពីគ្រូបង្រៀនគេជាដើម ។

ជាសរុប យោលទៅតាមកម្មវិធីសិក្សា និង យោលទៅតាមចំនេះដឹងចិត្តគរុកោសល្យរបស់លោកគ្រូ អ្នកគ្រូ ឪពុកម្តាយសិស្សសង្ឃឹមថា កូនគាត់នឹងឆ្លងចូលដោយងាយស្រួលទៅដំនាក់កាលលូតលាស់មួយថ្មីដោយគាត់ឃើញ ៖

១- កូនគាត់មានឫកពារត្រឹមត្រូវ មានពុទ្ធិ និងគំនិតល្អ

២- កូនមានពួកម៉ាកមានឫកពាប្រហែលនឹងកូនខ្លួន និងចូលចិត្តលេងជាក្រុមយ៉ាងស្និទ្ធស្នាល

ក្នុងអំឡុងវ័យកុមារភាព តាមការសិក្សា និងពិសោធន៍របស់ខ្ញុំ សិស្សានុសិស្ស ស្ថិតនៅក្នុងមជ្ឈដ្ឋានអប់រំល្អប្រសើរ ។ គេគោរពប្រតិបត្តិតាមការបង្រៀនប្រដៅរបស់ឪពុកម្តាយ និងលោកគ្រូ - អ្នកគ្រូ ដែលសរសើរមិនដាច់ពីមាត់ ពីការរីកលូតលាស់ល្អផ្នែករាងកាយ និង បញ្ញាស្មារតី ។ ល ។

ប៉ុន្តែ ស្រាប់តែដល់ពេលគេឡើងខ្លួន គេបញ្ចេញអាកប្បកិរិយា ចិត្តគំនិត និងសតិអារម្មណ៍ប្លែកពីកាលនៅក្នុងកុមារភាព ។ ពេលនេះឯងហើយ ដែលមានវិបត្តិតរុណវ័យ (crise de la puberté) [១]

**យ៉ន់ ធី**

( *តទៅលេខក្រោយ* )

(១) តាមចិត្តគរុកោសល្យ វិបត្តិតរុណវ័យ បង្កឡើងចំពេលកំពុងលូតលាស់ផ្នែកសតិបញ្ញា និងសរីរសាស្ត្រ (développement psycho-physiologique) នៃបុគ្គលិកនៅពេលឆ្លងកាត់ដំនាក់កាលមួយទៅដំនាក់កាលមួយ ដូចជាពេលផ្តាច់ដោះ ពេលរឹងរូសរបស់កុមារ ពេលពេញជំទង់ ពេលបញ្ចេញចរិតប្លែកនៃយុវភាព « ស្រីអាយុ ១៤ ឆ្នាំ ប្រុសប្រហែល ១៥ ឆ្នាំ » ។

# អំពើប្រល័យពូជសាសន៍ក្នុងសកលលោក

ដកចេញពីព្រឹត្តិប័ត្រ ០១៣ ខែ តុលា ១៩៩៦ របស់វេទិកាទូទៅនៃកម្ពុជា

## ការសំលាប់ជនជាតិជ្វីស (Juif)

**ការសំលាប់ជនជាតិ ជ្វីស** (Juif)

រវាងឆ្នាំ ១៩៤១ - ១៩៤៥ ជនជាតិជ្វីសនៅអឺរ៉ុបចំនួន ៥.១០០.០០០ នាក់ ត្រូវពួកណាស៊ី (Nazi) ហ៊ីត្លែរសំលាប់រង្គាល ។ តួលេខនេះមានបញ្ជាក់ក្នុងសៀវភៅ ការកំទេចជនជាតិជ្វីសនៅអឺរ៉ុប (La destruction des Juifs d' Europe) និពន្ធដោយលោក រ៉ាអ៊ុល ហ៊ីលប៊ែក (Raul Hilberg) ។ អ្នកស្រាវជ្រាវខ្លះទៀត បានរកឃើញចំនួនជនជាតិជ្វីសពី ៥ ទៅ ៦ លាននាក់ ដែលត្រូវគេសំលាប់កាលសម័យនោះ ។

លោក អ៊ីវ ទែណុង (Yves Ternon) បាននិពន្ធសៀវភៅឈ្មោះ រដ្ឋឧក្រិដ្ឋ (l' Etat criminel) បានកត់ត្រាចំនួនខ្លះ ស្តីពីការសំលាប់ជនជាតិជ្វីស ដូចជា ៖

១៥ % ស្លាប់ក្នុងទីប្រមូលផ្តុំ (Ghettos) និងពេលគេដឹកជញ្ជូន ជន្លៀស

២៥ % ត្រូវពួកសន្តិសុខ (SS) ពួកទាហាន ប៉ូលីស ជាអ្នកសំលាប់

៦០ % ត្រូវស្លាប់នៅជំរុំប្រមូលផ្តុំ អូស្វីត (Auschwitz) នាប្រទេសប៉ូឡូញ

មូលហេតុនៃការសំលាប់ គឺផ្តើមចេញពីគំនិតជាតិនិយមហួសហេតុ ការប្រកាន់ពូជសាសន៍ រឺការបំបាត់សិទ្ធិរស់នៅរបស់ជនជាតិជ្វីស ។ ហ៊ីត្លែរមានជំនឿថា ការសំលាប់ជនជាតិជ្វីស គឺជាការស្រោចស្រង់ប្រជាជាតិក្នុងទូទាំងសកលលោក និងការលើកស្ទួយជាតិសាសន៍អាល្លឺម៉ង់ជាចំបងលើសគេ ។ ជំនឿបែបនេះ មានប្រភពចេញពីរឿងដែលថា ពួកជ្វីសបានផ្តន្ទាទោសព្រះយេស៊ូគ្រីស្ត ដោយការដោតឆ្កាង ។ លោក ម៉ារទីន លូធែរ (Martin Luther) ដែលជាអ្នកបង្កើតសាសនា ប្រូតេស្តង់ ក៏ធ្លាប់បាននិយាយផ្តន្ទាទោសពួកជ្វីស ម្តងរួចមកហើយកាលឆ្នាំ ១៥៤៣ ។

អ្នកស្រាវជ្រាវនានាបានយល់ព្រមគ្នាថា ហ៊ីត្លែរ ជាមេគំនិតក្នុងការប្រល័យពូជសាសន៍ជ្វីស (Hitler fut le principal artisan du génocide Juif) តែគេមិនអាចដឹងថា ចាប់តាំងពីពេលណាមក ដែលហ៊ីត្លែរសំរេចអោយកំទេចជនជាតិជ្វីសនោះ ។

ជនជាតិស៊ីហ្គាន ដែលរស់នៅទ្វីបអឺរ៉ុប ក៏ត្រូវរងគ្រោះដោយអំពើប្រល័យពូជសាសន៍ ដែលអាល្លឺម៉ង់បានអនុវត្តក្នុងកំឡុងឆ្នាំ ១៩៤១ ដល់ ១៩៤៤ ផងដែរ ។ ប្រវត្តិវិទូខ្លះអះអាងថា ជនរងគ្រោះមានចំនួន ៥០០.០០០នាក់ ។ រីឯប្រភពខ្លះទៀត បានស្រាវជ្រាវឃើញថា ជនជាតិស៊ីហ្គាន ត្រូវស្លាប់តែត្រឹមចំនួន ២០០.០០០ ទៅ ២២០.០០០ ប៉ុណ្ណោះ ។

មូលហេតុនៃការសំលាប់ជនជាតិស៊ីហ្គាន គឺមកពីការប្រកាន់ពូជសាសន៍ ដែលពួកណាស៊ីយល់ឃើញថា ស៊ីហ្គាន ជាជនជាតិគ្មានជំនឿសាសនា ហើយក៏ជាជនជាតិក្រីក្រ ដែលនាំអោយសង្គមអាល្លឺម៉ង់កខ្វក់ បាត់ភាពថ្លៃថ្នូរ ។

## ការសំលាប់ជនជាតិ អារមេនី

អាណាចក្រទួរគី បានធ្វើផែនការនេះនៅចន្លោះខែ ធ្នូ ១៩១៤ រហូតដល់ ខែកុម្ភៈ ១៩១៥ ក្នុងពេលដែល ជនជាតិអារមេនី រស់នៅជាជនជាតិភាគតិច ក្នុងទឹកដីអាណាចក្រទួរគី ។ នៅឆ្នាំ១៩១៦ អាជ្ញាធរទួគី បានអនុវត្ត ផែនការប្រល័យពូជសាសន៍អារមេនី ដោយសំលាប់ជនជាតិនេះ ពី ១ លាន ដល់ ១,៥ លាននាក់ ។

មូលហេតុនៃការសំលាប់បំបាត់ពូជសាសន៍ អារមេនីនេះគឺ បណ្តាលមកពីទួរគីស្មានថា ជនជាតិអារមេនី បាន ចូលដៃជាមួយពួករុស្ស៊ី ក្នុងជំលោះរុស្ស៊ី - ទួរគី ។ ដូច្នេះ ទួរគីយល់ថា ជនជាតិអារមេនី គឺជាសត្រូវក្នុងប្រទេស ដែលជា គ្រោះថ្នាក់សំរាប់ទួរគី ។

## ការប្រល័យពូជសាសន៍នៅអតីតសហភាពសូវៀត

តាមសៀវភៅរដ្ឋឧក្រិដ្ឋរបស់លោក អ៊ីវទែរណុង (Yves Ternon) ដដែល ការសំលាប់ ការជន្លៀស ការបំបរ បង់ចោល និងការឃុំឃាំង ដោយបង្ខំអោយធ្វើការធ្ងន់ៗ ត្រូវគេអនុវត្តនៅសហភាពសូវៀត ក្នុងកំលុងចុងទសវត្សនៃឆ្នាំ ១៩៣០ រហូតដល់ ១៩៥៣ ។

លោក អាលិចសង់ ស៊ុលស្ទេនីតស៊ីន (Alexandre Suljenitsyne) និងលោក រ៉ូប៊ែរ កនក្វេស្ត (Robert Conquest) ប្រមាណថា ចំនួនមនុស្សស្លាប់ដោយអំពើប្រល័យពូជសាសន៍របស់សហភាពសូវៀត មានរហូតដល់ទៅ ២០ លាននាក់ ។

ការសំលាប់បែបនោះ គឺដើម្បីអនុវត្តដាច់ខាតនូវមនោគមវិជ្ជា ម៉ាក្ស (l' idéologie marxiste) ដែលមានទ្រឹស្តី ជាពិសេសអំពីការប្រកាន់សច្ចភាព (détenir la vérité) បំបាត់ទុគ៌តភាព និងការជិះជាន់មនុស្ស (Supprimer la misère et l'exploitation de l' homme par l' homme) ហើយនិងកសាងមាគ៌ា សមភាព និង សុភមង្គល (Tracer le chemin de l' égalité et du bonheur) ។

ម្យ៉ាងទៀត គឺដើម្បីកសាងសង្គមថ្មី ១ ចាប់ពីឆ្នាំ ១៩១៧ បន្ទាប់ពីរំលាយចោលសង្គមចាស់ពីកាលមុន ដោយធ្វើតាមមនោគមន៍វិជ្ជាម៉ាក្ស ដែលបានកំនត់អំពី សត្រូវរបស់វណ្ណៈ និងសត្រូវរបស់ប្រជាជន ។ បន្ថែមលើនេះ មានពីររូបគឺ ៖ លេនីន ត្រូវតែធ្វើអ្វីៗ ដើម្បីបក្ស និង ស្តាលីន ជាជនប្តេជ្ញាដាច់ខាត កាន់អំនាច រក្សាអំនាច ហើយ មានទេពកោសល្យខាងនិយាយកុហក និងខាងឧក្រិដ្ឋកម្ម ។

អំពើប្រល័យពូជសាសន៍ ក៏នៅមានទីផ្សេងៗទៀតដែរ ដូចជានៅកម្ពុជា មានរយៈពេលជិត ៤៥ ខែ ( មេសា ១៩៧៥ ដល់ មករា ១៩៧៩ ) ក្រោមការត្រួតត្រារបស់ពួកខ្មែរក្រហម និងនៅ រ៉វ៉ាន់ដា (Rwanda) នាឆ្នាំ ១៩៩៤ ។

អំពើប្រល័យពូជសាសន៍ គឺជាឧស្សាហកម្មផលិត សេចក្តីស្លាប់ តាមកម្មវិធីដែលគេបានស្រាវជ្រាវ ហើយចាត់ ចែងអោយមានជាក់ស្តែង ។ ដូច្នេះ អំពើនេះ ទោះបីចេញពីការសំរេចរបស់ជនណា ក្រុមណាក្តី ក៏ការអនុវត្តន៍ជាក់ស្តែង ដែលបង្កើតជាលទ្ធផលស្លាប់រង្គាលនេះ គឺមានឃុបឃិតពីស្ថាប័ន និង អង្គភាពរដ្ឋបាល អ្នកវិទ្យាសាស្ត្រ ហើយនិងអ្នក ជំនាញឯកទេសខាងបំបាត់ពូជសាសន៍ផងដែរ ។ ត្រង់នេះហាក់ដូចជាមានន័យថា សង្គមទាំងមូល ត្រូវជាប់ពិរុទ្ធ ។

ស្តីពីហេតុផលនៃអំពើប្រល័យពូជសាសន៍នេះ មជ្ឈដ្ឋានអ្នកនយោបាយ និងអ្នកជំនាញការផ្សេងៗ បានបង្ហាញទស្សនៈទីទៃពីគ្នា តាមលក្ខណៈជាគតិបណ្ឌិត ជានយោបាយ រឺជាតំរូវការតាមបច្ចុប្បន្ន ( les exigences du présent ) ។

ឧទាហរណ៍ លោក រីឆាត ហ្វូន វ៉ាយសេកយ័រ ( Richard von Weizsacker ) អតីតប្រធានាធិបតីអាល្លឺម៉ង់ បានថ្លែងសុន្ទរកថា នៅចំពោះមុខរដ្ឋសភាអាល្លឺម៉ង់ ថ្ងៃ ៨ ឧសភា ១៩៨៥ មានន័យសំដៅទៅរឿងពីអតីតកាលថា « សមូហភាព គ្មានពិរុទ្ធភាពអ្វីទាំងអស់ ។ គឺបុគ្គល ជាពិរុទ្ធជន រឺជាជនគ្មានទោសពៃរ៍ ។ យើងត្រូវទទួលស្គាល់អតីតកាល ទោះបីកាលនោះ យើងនៅជាបថមវ័យក្តី ហើយទោះបីយើងមានឈ្មោះ រឺគ្មានឈ្មោះជាពិរុទ្ធជនក្តី ។ យើងបានរស់នៅជាមួយផលវិបាកនៃអតីតកាល ដែលយើងទទួលខុសត្រូវទាំងស្រុង ។ យើងអាច ហើយត្រូវតែជួយគ្នាអោយបានយល់ទាំងអស់គ្នាថា ការរក្សាអតីតកាលអោយរស់រវើកនោះ គឺមានសារៈសំខាន់ណាស់ ។ នេះមិនមែនដើម្បីជំនះលើអតីតកាលប្តូរផ្លាស់ កែប្រែអតីតកាលទេ ។ ប៉ុន្តែ ជនដែលបិទភ្នែកមិនមើលអតីតកាល គឺជាជនខ្វាក់ក្នុងបច្ចុប្បន្ន ។ ជនដែលមិនចង់រំលឹកការឈឺចាប់ពីអតីតកាល ជននោះ នឹងពើបប្រទះគ្រោះថ្នាក់ថ្មីទៀត » ។

**តី ចាវច**

**នាយកវេទិកាទូទៅនៃកម្ពុជា**

---

អំពិល, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ខ្ញុំបាទឈ្មោះ ប៉ែន តាល់ គ្រូបង្រៀននៅសាលាបឋមសិក្សាអំពិល ភូមិអំពិល ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

សូមគោរពចូលមកគណៈកម្មាធិការនាយក ស.ប.ស.ខ.

សូមជ្រាប ។

ខ្ញុំសូមអស់លោកអនុញ្ញាតអោយខ្ញុំបាទសូមឆ្លើយនឹងប្រស្នារបស់លោក យ៉ង់ ធី ក្នុងទស្សនាវដ្តីគ្រូបង្រៀន លេខ ៤ ទំព័រ ៣៨ ដូចខាងក្រោមនេះ ។

ប្រស្នា : « ចំនេះដឹងគ្មានសីលធម៌ ជាការបំផ្លិចបំផ្លាញខ្លួនឯងតែប៉ុណ្ណោះ »

សំនួរ : ល្បះនេះសរសេរពីឆ្នាំណា ?

- ល្បះនេះជាល្បះមួយនៅក្នុងសំបុត្ររបស់លោក Gargantua ដែលគាត់បានសរសេរទៅកូនរបស់គាត់ឈ្មោះ Pantagruel ដែលកំពុងសិក្សានៅទីក្រុង Paris ដើម្បីជំរុញកូនអោយខិតខំរៀនជាខ្លាំងថែមទៀតដែលអ្នកនិពន្ធបានសរសេរពីឆ្នាំ ១៥៣២ ។

សតវត្សទីប៉ុន្មាន ?

- សតវត្សទី១៦ ដែលជាសតវត្សរស់ឡើងវិញរីនវកម្ម << siècle de la Renaissance >> ក្នុងប្រវត្តិអក្សរសាស្ត្របារាំង ។

ដោយអ្នកនិពន្ធឈ្មោះអ្វី ?

- ដោយអ្នកនិពន្ធម្នាក់ឈ្មោះ រ៉ាប៊ីឡេ Rabelais ( 1494 - 1553 )

* ទស្សនៈនេះឆ្លុះបញ្ចាំងអោយឃើញនូវ « តរុកោសល្យរបស់លោករ៉ាប៊ីឡេ » ដែលធ្វើអោយគាត់មានឈ្មោះល្បីរន្ទឺតាំងពីពេលនោះមកទល់ពេលនេះ ។

សូមអស់លោកទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់ឧត្តុង្គឧត្តមបំផុតអំពីខ្ញុំ ។

**ប៉ែន តាល់**

# វិញ្ញាសាប្រលងជ្រើសរើសនិស្សិតអធិការបឋមសិក្សាជំនាន់ទី ៣

( សម័យប្រលងថ្ងៃទី០៥ វិច្ឆិកា ១៩៩៦ )

*វិញ្ញាសាប្រលងមានបី តែដោយខ្វះទំព័រក្នុងទស្សនាវដ្ដី ខ្ញុំយកតែវិញ្ញាសាមួយ មកជូនលោកគ្រូ - អ្នកគ្រូពិចារណា ព្រោះអត្ថបទនេះ មានខ្លឹមសារផ្នែកវប្បធម៌ទូទៅ។ វិញ្ញាសានេះ មានមេគុណ ៤ និង រយៈពេល ៣ ម៉ោង។*

## វិញ្ញាសា : សិក្សាអត្ថបទ

ក្នុងពិភពលោកមួយដែលកំពុងមានការវិវត្តជាប្រចាំ ការអប់រំបានលេចឡើងជាឧបករណ៍សំខាន់បំផុតសំរាប់អោយមនុស្សជាតិអភិវឌ្ឍសង្គម ឆ្ពោះទៅរកឧត្តមគតិចង់អោយមានសន្តិភាព សេរីភាព យុត្តិធម៌សង្គម និងភាពសំបូររុងរឿង ។

ស្ថិតនៅចំពោះមុខបរិបទបច្ចុប្បន្ននៃពិភពលោក និងចំពោះមុខអនាគតដែលមានការប្រែប្រួលមិនឈប់ឈរនោះ តួនាទីនៃគ្រូបង្រៀនកាន់តែមានសារៈសំខាន់ជាអាយុជីវិត ។ កន្លងមក ដោយសារតួនាទីនេះហើយបានជាសេចក្ដីថ្លែងការណ៍ជាច្រើនត្រូវបានផ្សព្វផ្សាយក្នុងគោលបំណង ចង់លើកកំពស់គុណភាពនៃការបង្រៀន និងការរៀន ។

ការអង្កេតស្រាវជ្រាវថ្មីៗ នេះ នៅបណ្ដាប្រទេសជាច្រើនលើសកលលោក បានបង្ហាញអោយឃើញថាកុមារចំណាយពេលមើលទូរទស្សន៍ច្រើនជាងពេលរៀនក្នុងថ្នាក់រៀន ។ រីឯការផ្សព្វផ្សាយឃោសនា ក៏មានឥទ្ធិពលទៅលើមារយាទ និងទៅលើចំណង់របស់កុមារ ច្រើនជាងការសិក្សាអប់រំ ក្នុងសាលារៀនទៅទៀត ។

ម្យ៉ាងទៀត ដោយសារការរីកចំរើនឆាប់រហ័សនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងតាមរយៈការសិក្សាពីចំងាយ ការអប់រំបានជ្រួតជ្រាបបន្តិចម្ដងៗ រហូតដល់តំបន់ជនបទដាច់ស្រយាល ។ សព្វថ្ងៃនេះ វិទ្យុផ្សាយសំលេងថ្កោយរណប និងគ្រឿងទូរលេខផ្សេងៗ សុទ្ធតែបានរួមចំណែកដល់ការផ្សព្វផ្សាយការសិក្សាអប់រំ ហើយអ្នករៀនក៏អាចទាក់ទងឆ្លើយបានដោយងាយស្រួលជាមួយគ្រូរបស់ខ្លួនតាមរយៈទូរទស្សន៍ និងភាពយន្ត ។

ប៉ុន្តែពេលដែលយើងកាន់តែឈានចូលដល់សតវត្សទី ២១ខាងមុខនេះ តើយើងគប្បីយល់ដឹងអោយបានត្រូវដូចម្ដេចខ្លះទៅលើពាក្យ « គ្រូល្អ និងសិស្សល្អ » នោះ ? ជាការពិតណាស់ ចំលើយទៅនឹងសំនួរនេះ គឺអាចមានច្រើន ។

ការងារជាបន្ទាន់ចំពោះមុខនេះ គឺការចាប់បង្ខំអោយត្រូវតែកែលំអ និងលើកកំពស់ស្ថានភាពនៃគ្រូបង្រៀន ពោលគឺកែលំអការបណ្តុះបណ្តាល និងកែលំអទស្សនវិស័យតទៅមុខរបស់គេ ដើម្បីលើកកំពស់សមត្ថភាពអោយគេអាចឆ្លើយតបបានទៅនឹងតំរូវការ និង ចំណង់របស់កុមារក្នុងយុគសម័យថ្មីដែលពិភពលោកកំពុងមានការប្រែប្រួល និង អភិវឌ្ឍ ។ ធ្វើដូច្នេះ ក៏ដើម្បីរួមចំនែកផងដែរដល់ការកសាងជីវភាពរស់នៅរបស់មនុស្សដ៏សុខដុម និងដល់ការកសាងពិភពលោកមួយប្រកបដោយសន្តិភាព ។

គឺដោយសារមូលហេតុទាំងអស់នេះហើយ ទើបការណែនាំផ្តាំផ្ញើខាងក្រោមនេះ ត្រូវបានរៀបចំឡើងសំរាប់ជួយគ្រូបង្រៀនអោយខិតខំកែលំអ និងលើកកំពស់សមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន :

១. សិទ្ធិទទួលការអប់រំ គឺជាសិទ្ធិរបស់មនុស្សទាំងអស់នៃគ្រប់សង្គម ដោយគ្មានការបែងចែកអ្វីទាំងអស់អំពីជាតិសាសន៍ វណ្ណៈ ឋានៈ និងភេទ ។

២. ការអប់រំជាប្រចាំក្នុងជីវិត ត្រូវធានាសមត្ថភាពបួនយ៉ាង ដែលជាសសរគ្រឹះទាំងបួនសំរាប់ទ្រទ្រង់គុណភាពអប់រំ និងធ្វើអោយការអប់រំសំរេចគោលដៅ ។ នោះគឺ រៀនដើម្បីចេះដឹង រៀនដើម្បីចេះធ្វើ រៀនដើម្បីចេះរស់នៅជាមួយគ្នា និងរៀនដើម្បីចេះកសាងខ្លួន អោយប្រកបដោយសីលធម៌ល្អ ។

២.១. **រៀនដើម្បីចេះដឹង** ( Apprendre à connaître ) ដោយផ្សំវប្បធម៌ទូទៅដែលបានរៀន ជាមួយនឹងសមត្ថភាព និងលទ្ធភាពរៀនដោយខ្លួនឯងថែមទៀត អោយបានកាន់តែល្អសុក្រឹត និងលទ្ធភាពអាចធ្វើកិច្ចការបានកាន់តែស៊ីជំរៅ ទៅលើមុខវិជ្ជាផ្សេងៗ ទៀត ។ នេះគឺដូចពាក្យថា រៀនដើម្បីចេះរៀន ( Apprendre à apprendre ) ដើម្បីប្រើឱកាសដែលត្រូវបានផ្តល់អោយសំរាប់ទទួលការអប់រំជាប្រចាំក្នុងជីវិត អោយអស់លទ្ធភាព និងអោយបានផលប្រយោជន៍ ។

២.២. **រៀនដើម្បីចេះធ្វើ** ( Apprendre à faire ) ដើម្បីមិនត្រឹមតែចេះទទួលគុណភាពនៃវិជ្ជាជីវៈប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានសមត្ថភាពចេះប្រឈមមុខបានទៅនឹងបញ្ហានានា និងចេះប្រកបការងារក្នុងជីវភាពគ្រួសារ និងជីវភាពសង្គមថែមទៀត ។ នេះគឺមានន័យម្យ៉ាងទៀតថា រៀនដើម្បីចេះធ្វើការងារអ្វីមួយក្នុងក្របខ័ណ្ឌនៃបទពិសោធន៍ផ្សេងៗ ក្នុងគ្រួសារ និងក្នុងសង្គម រឺក្នុងក្របខ័ណ្ឌការងារដែលអាចមានដោយឯកឯង សមស្របទៅនឹងបរិបទរបស់មូលដ្ឋានរឺរបស់ប្រទេសជាតិ ក្នុងក្របខ័ណ្ឌការងារដែលអាចមានដោយស្របច្បាប់ អាស្រ័យដោយការរីកចំរើននៃការសិក្សាអប់រំពីចំងាយ និងការសិក្សាអប់រំតាមរូបភាពឆ្លាស់ពេលគ្នា ។

២.៣. **រៀនដើម្បីចេះរស់នៅជាមួយគ្នា** ( Apprendre à vivre ensemble ) ដោយពង្រីកការយល់ដឹងអំពីអ្នកដទៃ និងភាពជាចំនុះគ្នាទៅវិញផងទៅមក ដើម្បីធ្វើអោយសំរេចគោលដៅដូចគ្នា ក្នុងគោលបំនង ចង់អោយមានការយោគយល់គ្នា ចង់អោយស្គាល់តំលៃនៃពហុនិយម ( Pluralisme ) និងតំលៃនៃសន្តិភាព ឈានទៅលប់បំបាត់ចោលនូវជំលោះផ្សេងៗ ក្នុងសង្គម និងក្នុងពិភពលោកទាំងមូល ។

**២.៤. រៀនដើម្បីចេះកសាងខ្លួនអោយប្រកបដោយសីលធម៌ល្អ** ( Apprendre à être ) ដោយពង្រីកបុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ៗ អោយចេះពិចារណា និងចេះធ្វើសកម្មភាពដោយត្រឹមត្រូវ និងអោយមានស្មារតីទទួលខុសត្រូវដោយខ្លួនឯង ។ ក្នុងន័យនេះ គេមិនអាចធ្វេសប្រហែសបានឡើយ អំពីសក្ដានុភាពរបស់បុគ្គលដែលត្រូវមានសមត្ថភាពខាងការពិចារណា ការចងចាំ សមត្ថភាពខាងសោភ័ណ ខាងរាងកាយ - ល - ។

**៣.** ដូចនេះប្រព័ន្ធអប់រំ ត្រូវឆ្ពោះទៅរកការផ្ដល់អាទិភាព អោយដល់ការផ្ទេរចំនេះដឹងប្រកបដោយគុណភាព និងត្រូវកែលំអអ្វីដែលជាការនាំអោយខូចប្រយោជន៍ដល់ការសិក្សាអប់រំដោយត្រូវយល់ដឹងថា ការអប់រំគឺជាវត្ថុទាំងមូល ។ តទៅអនាគត ការមើលឃើញបែបនេះ ត្រូវតំរង់ឆ្ពោះទៅរកការកែទំរង់ការអប់រំដើម្បីប្រសិទ្ធិភាព និងគុណភាព ក្នុងការកសាងកម្មវិធីសិក្សា រឺការកំនត់និយមន័យ អោយដល់នយោបាយថ្មីខាងគរុកោសល្យ ។ . . . »

## សំនួរ

១. ការទទួលការអប់រំ គឺជាសិទ្ធិរបស់មនុស្សទាំងអស់ ។

តើត្រូវធ្វើដូចម្ដេច ដើម្បីអនុវត្តសិទ្ធិនេះអោយមានប្រសិទ្ធិភាព ? ( ៤ពិន្ទុ )

២. តើពិភពលោកសព្វថ្ងៃ មានការប្រែប្រួលអ្វីខ្លះ លើផ្នែកសង្គម និងផ្នែកបច្ចេកទេស ?

តើការប្រែប្រួលនោះ មានឥទ្ធិពលអ្វីខ្លះដល់ការអប់រំ ? ( ៤ពិន្ទុ )

៣. ផ្ដើមចេញពីអត្ថបទនេះ ក្នុងឋានៈជាអធិការបឋមសិក្សា តើអ្នកត្រូវនែនាំអ្វីខ្លះដល់គ្រូបង្រៀន ដើម្បីពង្រឹងបន្ថែមទៀតនូវគុណភាពនៃការបង្រៀន និងការរៀន ?

តើការបង្រៀនល្អទាមទារអោយគ្រូបង្រៀន ត្រូវរៀបចំកិច្ចតែងការបង្រៀនដូចម្ដេចខ្លះ ?

ចូរបកស្រាយដោយលើកយកឧទាហរណ៍ក្នុងការបង្រៀនមេរៀនអំនាន រឺគណិតវិទ្យាណាមួយនៅបឋមសិក្សាមកបញ្ជាក់ ។ ( ១២ពិន្ទុ )

## ចាប់ខ្លួនសមស្ងួនជាងចាប់កេរ្តិ៍ឈ្មោះ

<< . . . . Dans un monde en évolution permanente, l'éducation apparaît comme un atout indispensable pour permettre à l'humanité de progresser vers les idéaux de paix, de liberté, de justice sociale et de prospérité.

Face à ce contexte mondial et aux défis de son avenir, le rôle des enseignants devient de plus en plus vital et a déjà fait l'objet de nombre de déclarations et d'écrits au profit du renforcement de la qualité de l'enseignement et de l'apprentissage.

Selon les enquêtes récentes, dans un certain nombre de pays dans le momde, les enfants passent davantage de temps à regarrder la télévision que dans la salle de classe et les médias influencent davantage leurs comportements et leurs aspirations que l'enseignement dispensé à l'école.

En outre, grâce au recours croissant à la science et à la technologie, l'éducation, par le biais de l'enseignement à distance, touche peu à peu les zones rusales et reculées. La radio, le satellite ou le câble contribuent maintenant à dispenser l'enseignement et les apprenants communiquent essentiellement avec leurs enseignants à travers un écran.

Cependant, au fur et à mesure que nous approchons du XXI$^{ème}$, qu'est - ce que nous entendons exactement par le terme "un bon enseignant et un bon apprenant " ? Les réponses à cette question pourraient être multiples.

Des actions urgentes s'imposent pour améliorer la formation et les perspectives d'avenir des enseignants afin qu'ils soient en mesure de mieux répondre aux besoins et aux aspirations des enfants, et ce faisant, contribuer de manière significative à la construction d'un mode de vie sain et d'un monde de paix.

Voilà pourquoi les recommandations ci - dessous pourraient être envisagées pour permettre aux enseignants de s'améliorer et de perfectionner leurs compétences professionnelles :

1. Le droit à l'éducation est le droit de tout le monde dans toutes les sociétés sans aucune discrimination de nationalité, de race, de classe et de sexe.

2. L'éducation tout au long de la vie est fondée sur quatre piliers : apprendre à connaître, apprendre à faire, apprendre à vivre ensemble et apprendre à être.

2.1. Apprendre à connaître, en combinant une culture générale acquise avec la capacité et la possibilité de se perfectionner et de travailler en profondeur un petit nombre de matières. Ce qui veut dire aussi : apprendre à apprendre pour bénéficier des opportunités offertes par l'éducation tout au long de la vie.

2.2. Apprendre à faire, afin d'acquérir non seulement une qualification profesionnelle mais, plus largement, une compétence qui rend apte à faire face à de nombreuses situations et à travailler dans la vie familiale et sociale. Ce qui veut dire aussi : apprendre à faire dans le cadre des diverses expériences familiales et sociales ou de travail qui s'offrent aux jeunes et adolescents, soit spontanément par suite du contexte local ou national, soit formellement grâce au développement de l'enseignement à distance et l'enseignement par alternance.

2.3. Apprendre à vivre ensemble, en développant la compréhension de l'autre et la perception des interdépendances pour réaliser des objectifs communs et se préparer à gérer les conflits dans le respect des valeurs de pluralisme, de compréhension mutuelle et de paix dans le monde.

2.4. Apprendre à être, pour mieux épanouir sa personnalité et être en mesure d'agir avec une capacité d'autonomie, de jugement et de responsabilité personnelle. A cette fin ne négliger dans l'éducation aucune des potentialités de l'individu : mémoire, raisonnement, sens esthétique, capacité physique, aptitude à communiquer . . .

3. Alors que les systèmes éducatifs formels tendent à privilégier l'accès à la connaissance au détriment des autres formes d'apprentissage, il importe de concevoir l'éducation comme un tout. Cette vision doit, à l'avenir, inspirer et orienter les réformes éducatives, que ce soit dans l'élaboration des programmes ou la définition de nouvelles politiques pédagogiques . . . >>

*
* *

## Questions

1- Comment fait - on pour mettre en œuvre le droit pour tous à l'éducation avec efficacité ? **( 4 points )**

2- Qu'est - ce qui est en changement dans le monde d'aujourd'hui ? Quelles influences ces changements aussi bien sociaux que techniques exercent sur l'éducation ? **( 4points)**

3- A partir de ce texte, en tant qu'Inspecteur de l'enseignement primaire, quelles consignes donneriez - vous aux enseignants en faveur du renforcement de la qualité de l'enseignement et de l'apprentissage ? Comment l'enseignant doit - il faire la préparation de classe pour s'assurer d'un bon enseignement ? Expliquez à l'aide d'exemples concrets à partir d'une leçon de lecture ou de mathématiques au niveau primaire. **(12 points)**.



# គរុកោសល្យ & ការគ្រប់គ្រង

## ដើម្បីបង្រៀនមេរៀនមួយបានល្អ តើលោកគ្រូ - អ្នកគ្រូ ត្រូវពិចារណាលើបញ្ហាអ្វីខ្លះ ?

គ្រូបង្រៀនមានភារកិច្ចធ្ងន់ធ្ងរ ក្នុងការកែច្នៃសិស្សអោយក្លាយជាពលរដ្ឋថ្លៃថ្នូរបស់ប្រទេសជាតិ មានបញ្ញាស្មារតី មានចំនេះដឹងវិទ្យាសាស្ត្រគ្រប់គ្រាន់ អាចបំរើការងារក្នុងជីវភាពប្រចាំថ្ងៃរបស់គេបានតាមសំនូមពរ ។ គ្រូល្អ គឺគ្រូដែលចេះបង្កបរិយាកាសគរុកោសល្យនៅក្នុងថ្នាក់រៀនបានល្អ ហើយតែងបានទទួលលទ្ធផលល្អពីភារកិច្ចរបស់ខ្លួន ព្រោះគេតែងយលច្បាស់ពីក្មេង គេដឹងពីអ្វីដែលក្មេងស្រឡាញ់ចូលចិត្ត និងពីអ្វីដែលមានប្រយោជន៍ចំពោះសិស្ស ។ គ្រូបង្រៀនមិនត្រូវយល់ច្រលំដាច់ខាត់ថា សិស្សអាចយល់នូវអ្វីៗ ទាំងអស់ ដែលគ្រូបានបង្រៀនគេនោះទេ តែគ្រូត្រូវចេះប្រើប្រាស់ពុទ្ធិរបស់ខ្លួននៅក្នុងចិត្តសាស្ត្រ នឹងយល់ដឹងនូវការរីកលូតលាស់របស់កុមារជានាទាបានការពង្រឹង និងលើកទឹកចិត្តគេអោយខិតខំរៀនសូត្រ ។

ហេតុនេះ ដើម្បីបង្រៀនមេរៀនមួយបានល្អសមស្របតាមកម្មវិធីសិក្សា តាមវិធីសាស្ត្រ និងល្បិចក្នុងការបង្រៀន លោកគ្រូ - អ្នកគ្រូ ត្រូវយកចិត្តទុកដាក់លើបញ្ហា ៥ចំនុចគឺ ៖

១. មុខវិជ្ជាដែលត្រូវបង្រៀន ( La matière à enseigner )

២. បែបបទនៃការបង្រៀន ( La manière d'enseigner )

៣. គ្រូដែលជាអ្នកបង្រៀន ( Le maître qui enseigne )

៤. សិស្សដែលត្រូវបានគ្រូបង្រៀន ( Les élèves enseignés )

៥. លទ្ធផលដែលទទួលបានពីការបង្រៀន ( Les fruits de l'enseignement )

### ក. មុខវិជ្ជា រឺ មេរៀនដែលគ្រូបង្រៀន

មេរៀនទីមួយៗ ដែលគ្រូលើកយកមកបង្រៀនមានសារៈសំខាន់ណាស់ ក្នុងការផ្សារភ្ជាប់នឹងកម្មវិធីសិក្សាតាមកំរិតថ្នាក់របស់សិស្ស ផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែងរបស់មូលដ្ឋាន ។ រាល់មេរៀនត្រូវយកចិត្តទុកដាក់លើអត្ថរស និងអត្ថរសនៃខ្លឹមសារ :

+ **អត្ថន័យនៃខ្លឹមសារមេរៀន** : ( le fond ) ខ្លឹមសារមេរៀន ត្រូវជាក់ច្បាស់ពិតប្រាកដ មិនភ័ន្តច្រឡំមិនមានការមន្ទិលសង្ស័យ មិនមានការនិយាយស្តីមិនសមរម្យ មិនបំផ្លើស ។ មេរៀនត្រូវមានលក្ខណៈគ្រប់គ្រាន់មិនវែងពេក មិនខ្លីពេក សមស្របតាមកំរិតយល់ដឹងរបស់សិស្ស មិនពិបាកពេកតែក៏មិនស្រួលពេកដែរ ។

+ **អត្ថរូបនៃមេរៀន** : ( le forme មេរៀនត្រូវមានគំរោងត្រឹមត្រូវ បែងចែកកឋាខ័ណ្ឌច្បាស់លាស់ ត្រូវមានទំនាក់ទំនងជាប្រព័ន្ធជាមួយមេរៀនចាស់ និង ត្រៀមលក្ខណៈភ្ជាប់ទៅនឹងមេរៀនបន្ទាប់ ។

## ខ. បែបបទនៃការបង្រៀន

ចំពោះបែបបទនៃការបង្រៀន លោកគ្រូ - អ្នកគ្រូ ត្រូវអនុវត្តល្អ តាមលំនាំនៃការបង្រៀន ។ ជាមួយនេះដែរ ត្រូវគិតដល់វិធីសាស្ត្រដែលត្រូវយកមកបង្រៀន អាចជាវិធីបិតក្នុងទំរង់ចោទសួរ រឺ រាយរាប់ រឺ ទំរង់ស្រាវជ្រាវដោយបុគ្គល រឺក្រុមសិស្ស ។ គ្រូបង្រៀនអាចយកវិធីតាមទំរង់បែបណាក៏បាន អោយតែស្របតាមមុខវិជ្ជា និង មេរៀនដែលត្រូវបង្រៀនសិស្ស ។ ទន្ទឹមនឹងវិធីបង្រៀន គ្រូបង្រៀនត្រូវមានល្បិចផ្សេងៗ ក្នុងការបង្រៀនសិស្សថែមទៀត ដើម្បីអោយការបង្រៀនកាន់តែស៊ុក្រឹត ។ ល្បិចបង្រៀនទាំងនោះ អាចមានការវិភាគ រឺសំយោគ អនុមាណរួម គឺអនុមាណញែក ល្បិចអព្ភន្តរញាណ ល្បិចប្រៀបធៀប ល្បិចប្រើប្រាស់ក្តារខៀន . . . ។ល ។ ក្នុងការដាក់អោយសិស្សអនុវត្តមេរៀនទីមួយៗ លោកគ្រូ - អ្នកគ្រូ ត្រូវយកចិត្តទុកដាក់លើការអនុវត្តដោយបុគ្គល រឺដោយក្រុមសិស្ស ដោយការធ្វើត្រាប់តាមគំរូរបស់គ្រូ រឺដោយការច្នៃប្រឌិតបង្កើតដោយផ្ទាល់របស់សិស្ស ។ រាល់ចំនុច រឺសំនួរដែលដាក់អោយសិស្សអនុវត្តមេរៀនត្រូវមានលក្ខណៈគ្រប់គ្រាន់ និងប្រកបដោយវិចារណញ្ញាណ ។ ចំពោះការត្រួតពិនិត្យមេរៀន ដើម្បីតាមដានការយល់ដឹងរបស់សិស្ស គ្រូអាចអនុវត្តរួម រឺជាបុគ្គលដោយឡែកៗ ។

## គ. គ្រូដែលជាអ្នកបង្រៀនផ្ទាល់ដល់សិស្ស

គ្រូបង្រៀនល្អ គឺគ្រូដែលមានសិល្បៈក្នុងការដែលចេះបង្ហាញខ្លួន ចេះនិយាយ និង សរសេរ ចេះបញ្ចុះបញ្ចូល និងធ្វើអោយគេពេញចិត្ត ចេះធ្វើអោយគេយល់ អោយសិស្សចេះស្រាវជ្រាវ និងចេះយកទៅអនុវត្តជាក់ស្តែង ។

*គេអាចកំនត់បាននូវ* ៖

- **សំលៀកបំពាក់** : ស្អាតបាត សាមញ្ញ សមរម្យ សមហេតុផល និងមិនធ្វេសប្រហែស ។
- **ភាសានិយាយ** : ច្បាស់ និង ត្រឹមត្រូវ របៀបនិយាយច្បាស់លាស់ចេញពីធម្មជាតិ និង ប្រកបដោយសមានចិត្ត ។
- **សំនួររបស់គ្រូ** : ងាយអាន ស្អាត មានសណ្តាប់ធ្នាប់ មានប្រយោជន៍ និង ត្រឹមត្រូវតាមវេយ្យាករណ៍ និង អក្ខរាវិរុទ្ធ ។
- **ឫកពារ** : ថ្លៃថ្នូរ ស្វាហាប់ រីករាយ និងធ្វើអោយគេចាប់អារម្មណ៍ ។
- **កាយវិការ** : ផុសចេញពីធម្មជាតិ មានទឹកមុខស្រស់ស្រាយ និងមិនបញ្ចេញនូវកំហឹង រឺពាក្យប្រទ្បើសបើស ។

- កោសល្យ : មានបំនិនប្រសប់ក្នុងការធ្វើអ្វីមួយជាលក្ខណៈវិទ្យាសាស្ត្រ និងមានជំនឿច្បាស់លើខ្លួនឯង ដោយសមានចិត្ត និងដោយចិត្តសាស្ត្រវាងវៃ ដោយការងាយស្រួល និងច្បាស់លាស់ ដោយសេចក្ដីក្លៀវក្លា និងដោយស្វាហាប់បំផុត . . . ។




សិស្សរៀនប្រើឧបករណ៍សិក្សាដោយយកចិត្តទុកដាក់

## ឃ. សិស្សដែលត្រូវបានគ្រូបង្រៀន

លោកគ្រូ - អ្នកគ្រូគួរយល់ថា នៅថ្នាក់រៀនមួយ សិក្សានុសិស្សតែងមានវ័យខុសគ្នា មានមាឌខុសគ្នា មានសុខភាព និងជីវភាពរស់នៅមិនដូចគ្នាទាំងអស់ទេ មានបុកពារផ្សេងៗ គ្នា ហើយក៏មានកំរិតយល់ដឹងមិនស្មើគ្នាដែរ ។ ជាពិសេសកុមារ ពុំមែនជាមនុស្សធំដែលនៅតូចនោះទេ ដូចនេះបញ្ហារបស់កុមារ ពុំអាចចាត់ទុកថា ជាបញ្ហារបស់មនុស្សចាស់ឡើយ ។ ក្នុងការបង្រៀនសិស្ស ដើម្បីអោយសិស្សមានសកម្មភាពល្អ គ្រូត្រូវណែនាំសិស្សអោយចេះសង្កេត ស្ដាប់ ស្រាវជ្រាវ ពិសោធន៍ ឆ្លើយសំនួរខ្លីៗ កត់ត្រា រៀបរាប់ គូរ ប្រៀបធៀប ចេះកំនត់នូវបញ្ហាសំខាន់ៗ . . . ។ សំនួរខ្លីៗ របស់សិស្សម្នាក់ៗ ត្រូវច្បាស់ មានខ្លឹមសារត្រឹមត្រូវ និង សមស្របតាមតំរូវការជាក់ស្ដែង ។ ជាមួយនេះដែរ គ្រូត្រូវគិតលើគុណភាព និងតំលៃនៃចំលើយរបស់សិស្សតបវិញផងដែរ ។ រាល់ពេលបង្រៀនសិស្ស កត្តាសំខាន់គឺវិន័យរៀនសូត្ររបស់សិស្ស ដែលអាចនាំមកនូវបំរុងប្រយ័ត្ន ។ ហេតុនេះ លោកគ្រូ - អ្នកគ្រូ ត្រូវយកចិត្តទុកដាក់អោយបានល្អលើការត្រួតពិនិត្យ ការសរសើរ លើកទឹកចិត្ត និងកែលំអអោយបានញឹកញាប់នូវវិន័យរបស់គេក្នុងថ្នាក់រៀន ។

## ង. លទ្ធផលនៃការបង្រៀន

វិធីសាស្ត្រ និងល្បិចបង្រៀនមានច្រើនបែបច្រើនយ៉ាង អាស្រ័យលើមុខវិជ្ជា និង មេរៀននីមួយៗ ដែលលោកគ្រូ - អ្នកគ្រូលើកយកមកបង្រៀនសមស្របតាមកំរិតថ្នាក់របស់សិស្ស ប៉ុន្តែបញ្ហាដែលសំខាន់បំផុត គឺផ្លែផ្កា រឺលទ្ធផលដែលសិស្សទទួលបានពីការបង្រៀនរបស់គ្រូដល់គេ ។ ចំនុចខាងក្រោមនេះ ជាគន្លឹះឆ្លុះបញ្ចាំងនូវលទ្ធផលនៃការបង្រៀនរបស់គ្រូដល់សិស្ស ។

- សិស្សបានយល់មេរៀនច្បាស់លាស់ ចូលចិត្តនឹងយល់ស្របតាមការបង្រៀនរបស់គ្រូ សិស្សមានលំនឹកកម្មល្អ មិនភ្លេចភ្លាំង និងអនុវត្តបានដោយផ្សារភ្ជាប់នឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់គេ ។

- គ្រូបានធ្វើអោយរីកចំរើននូវគំនិតបញ្ញារបស់សិស្សមាន : ចេះសង្កេត ចេះប្រើប្រាជ្ញាមួយណ៍ ចេះប្រើវិចារ ចេះវិនិច្ឆ័យ ចេះសញ្ជឹងគិត ចេះដោះស្រាយបញ្ហា មានកោសល្យ . . . និងបណ្ដុះបណ្ដាលគេអោយមានការរីកចំរើនផ្នែកសីលធម៌ និង សង្គមធម៌ ទំនៀមទំលាប់ រឺ សោភ័ណ - ល - ។

លទ្ធផលដែលទទួលបានសំរេចជោគជ័យ អាស្រ័យដោយកត្តាជាច្រើនសំរាប់គ្រូ និងសិស្ស តែយើងលើកយកតែកត្តា ៣ សំខាន់គឺ › បញ្ញា ( l'intelligence ) កិច្ចការដែលធ្វើ ( le travail ) វិធីសាស្ត្រ (la méthode) ។ លើកត្តាទាំង ៣ គេអាចកំនត់ថា បញ្ញាមានកំរិតខ្ពស់ មធ្យម រឺទាប កិច្ចការដែលធ្វើមានលក្ខណៈអស្ចារ្យប្លែកពីគេសាមញ្ញធម្មតា រឺមិនសមស្រប រីឯវិធីសាស្ត្រមានចរិតប្រសើរបំផុត ល្អ រឺអាក្រក់ខ្លាំង ។ ដូចនេះ គេអាចវាយតំលៃបានថា អ្វីដែលល្អ គឺដោយមានប្រាជ្ញាខ្ពង់ខ្ពស់ បំពេញការងារប្រកបដោយខ្លឹមសារ ស៊ីជំរៅ ដោយចាប់ផ្ដើមពីគ្រឹះបន្ទាប់មកគឺមានវិធីសាស្ត្រ និងល្បិចប្រសើរបំផុត ។ ចំនែកអ្វីដែលមិនសូវល្អ គឺបញ្ញាទន់ខ្សោយធ្វើការងារតិចតួច និងគ្មានវិធីសាស្ត្រសោះ ។ កត្តាទាំងនេះបង្ហាញនូវការប្រែប្រួលយ៉ាងធំធេងនៃលទ្ធផលការងាររបស់គ្រូ - សិស្ស ។

ក្នុងការបង្រៀនសិស្ស គេតែងជួបប្រទះនូវគ្រូបង្រៀនបីប្រភេទ :

១. គ្រូបង្រៀនដែលគិតតែខ្លួនឯងផ្ទាល់មានចរិត : អំនួត រឺ ខ្ជិលច្រអូស . . .

២. គ្រូបង្រៀនដែលគិតតែទៅលើមុខវិជ្ជាណាមួយមានចរិត : អន់បំផុត រឺ មិនប្រសប់

៣. គ្រូបង្រៀនដែលគិតតែទៅលើសិស្សមានចរិត : ជាចិត្តវិទូ តែងទទួលបានលទ្ធផលល្អប្រសើរញឹកញាប់

គឺដោយសារផ្អែកលើបុគ្គលលក្ខណៈខាងលើនេះ ដែលលោកគ្រូ - អ្នកគ្រូបង្រៀន នឹងបង្ហាត់បង្ហាញសិស្ស ។ គុណភាពអប់រំសិស្សបានតិច ព្រោះតែគ្រូនិយាយច្រើន គុណភាពអប់រំបានខ្ពស់ ព្រោះតែសិស្សអនុវត្តសកម្មភាពបានច្រើន ហើយគ្រូអប់រំសិស្សបានញឹកញាប់ ពីព្រោះគេទទួលបន្ទុកជាអ្នកអប់រំ ។

**មិនមាក់ងាយ មិនស្រលាញ់ហួសហេតុពេក**

**លើវិធីបង្រៀនណាឡើយ ប៉ុន្តែត្រូវចេះជ្រើសរើសប្រកបដោយគតិបណ្ឌិត**

លោក **ថោង ស៊ីនតូ**

អធិការបឋមសិក្សា

អនុប្រធានមន្ទីរអប់រំ យុវជន និង កីឡា ខេត្តកណ្ដាល

# ការជ្រើសរើស និង ការអនុវត្តវិធីសាស្ត្រនៃការបង្រៀន

កន្លងមកនេះ វិស័យអប់រំកម្ពុជាយើង បានជួបប្រទះនូវវិបត្តិយ៉ាងធ្ងន់ធ្ងរ នោះគឺកំសោយរបស់សិស្ស ។បញ្ហានេះត្រូវបានរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងអប់រំ យុវជន និង កីឡា ដែលជាអ្នកទទួលបន្ទុកផ្ទាល់ ដោយមានការឧបត្ថម្ភគាំទ្រទាំងស្មារតី និង ទាំងសំភារៈ ថវិការបស់អង្គការអន្តរជាតិនានា បានចាត់តាំងសកម្មភាពបណ្តុះបណ្តាលផ្សេងៗ ដូចជាបើកវគ្គវិក្រឹតការ សិក្ខាសាលា និង បើកវគ្គបណ្តុះបណ្តាលគរុកោសល្យនៅភ្នំពេញ ក៏ដូចជានៅបណ្តាខេត្ត ក្រុងនានាជាច្រើនលើក ក្នុងបំនងស្តារ និងលើកកំពស់គុណភាពអប់រំ ។ តែពិនិត្យជារួម រហូតមកដល់ពេលនេះ ការរីកចំរើននៃវិស័យអប់រំរបស់យើងឃើញថា មានការរីកចំរើនលើបរិមាណ តែបើពិនិត្យលើគុណភាពឃើញថា មានការរីកចំរើនបានតែមួយជំហានប៉ុណ្ណោះ ពោលគឺនៅពុំទាន់ឆ្លើយតបនឹងគោលបំនងរបស់រាជរដ្ឋាភិបាល របស់ក្រសួងនិងរបស់យើងទាំងអស់គ្នានៅឡើយទេ ។ ប្រការនេះ បានធ្វើអោយយើងនៅតែមានការព្រួយបារម្ភ ចំពោះវាសនានៃវិស័យអប់រំរបស់យើង ហើយតំរូវអោយយើងរកវិធីដោះស្រាយកែលំអជាបន្តបន្ទាប់ដោយឥតឈប់ឈរ ។

ដើម្បីដោះស្រាយបញ្ហាដែលរៀបរាប់ខាងលើ ចាំបាច់យើងត្រូវរកមូលហេតុអោយឃើញ តើកត្តាអ្វីខ្លះ ដែលបានជះឥទ្ធិពលដល់ការសិក្សាទាំងមូល ជាពិសេសដល់កំសោយរបស់សិស្ស ? ចំលើយនៃសំនួរនេះមានច្រើនណាស់ ហើយចំលើយនីមួយៗ សុទ្ធតែមានមូលហេតុសមស្រប និងពាក់ព័ន្ធគ្នា នោះគឺការធ្លាក់ចុះនៃវិស័យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងនយោបាយសង្គមរបស់យើង ក្រោយពេលឆ្លងកាត់សង្គ្រាមជាបន្តបន្ទាប់ ។ តែក្នុងនោះ ក៏គេពុំត្រូវភ្លេចលើកយកមកនិយាយផងដែរ នូវកត្តាផ្សេងៗ ជាច្រើនទៀតមានជាអាទិ៍ កត្តាគ្រូបង្រៀនដែលជាអ្នកបង្ហាត់បង្រៀន និង កត្តាសិស្សដែលជាអ្នករៀនផ្ទាល់ ។

ខាងក្រោមនេះ យើងសូមលើកយកតែបញ្ហាដែលទាក់ទងនឹងកត្តាលោកគ្រូ - អ្នកគ្រូ ដែលជាអ្នកទទួលខុសត្រូវផ្ទាល់ ក្នុងការលើកកំពស់គុណភាពអប់រំ នោះគឺការលើកកំពស់សមត្ថភាពខ្លួនឯង ការជ្រើសរើសនឹងការអនុវត្តវិធីសាស្ត្រនៃការបង្ហាត់បង្រៀន ដែលលោកគ្រូ - អ្នកគ្រូម្នាក់ៗ អាចដោះស្រាយបានដោយខ្លួនឯង ។ ចំពោះកត្តាផ្សេងៗ ទៀត យើងពុំបានលើកយកមកដោះស្រាយនាពេលនេះទេ ព្រោះថា កត្តាខ្លះមានលក្ខណៈធំធេង ដែលជាភារកិច្ចរបស់រាជរដ្ឋាភិបាល និងរបស់សង្គមទាំងមូលជាអ្នកដោះស្រាយ ។

## ១. អំពីការជ្រើសរើសវិធីសាស្ត្របង្រៀន

ការជ្រើសរើសវិធីសាស្ត្របង្រៀន ជាបញ្ហាមួយសំខាន់ ហើយក៏ជាកង្វល់របស់លោកគ្រូ - អ្នកគ្រូផងដែរក្នុងពេលជ្រើសរើសយកមេរៀនណាមួយមកបង្រៀនសិស្ស ។

ពីរបីឆ្នាំចុងក្រោយនេះ លោកគ្រូ - អ្នកគ្រូបានទទួលវិធីសាស្ត្របង្ហាត់បង្រៀនថ្មីៗ ជាច្រើន តាមរយៈការបណ្តុះបណ្តាលរយៈពេលខ្លី - រយៈពេលវែង តាមរយៈសិក្ខាសាលា និងតាមរយៈសន្និសីទនានា ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការអន្តរជាតិនានា ដែលបានមកជួយឧបត្ថម្ភគាំទ្រដល់ការកែប្រែ និងការលើកកំពស់គុណភាពអប់រំនៅកម្ពុជា ។ នៅពេលដែលលោកគ្រូ - អ្នកគ្រូ បានទទួលវិធីសាស្ត្របង្ហាត់បង្រៀនកាន់តែច្រើន កង្វល់របស់លោកគ្រូ - អ្នកគ្រូកាន់តែមានច្រើនដែរ ។ មានលោកគ្រូ អ្នកគ្រូយើងខ្លះបាននិយាយថា សព្វថ្ងៃនេះមិនដឹងបង្រៀនតាមវិធីបង្ហាត់បង្រៀនណាទេ បើអង្គការនេះបានលើកយកវិធីសាស្ត្របង្រៀនរបៀបនេះ ហើយអង្គការផ្សេងទៀត បានលើកយកវិធីសាស្ត្រផ្សេងទៀតនោះ ។ បើយកតាមវិធីសាស្ត្របង្រៀនបែបនេះ រឺបែបនោះក្រែងវាខុស ជាពិសេសខ្លាចខុសនឹងទឹកចិត្តរបស់លោកប្រធានមន្ទីរអប់រំយុវជន និងកីឡា លោកអធិការ លោកនាយកសាលា រឺរបស់លោកប្រធានក្រុមបច្ចេកទេស ។ ការព្រួយបារម្ភ និងកង្វល់របស់លោកគ្រូ - អ្នកគ្រូ ស្តីពីការជ្រើសរើសវិធីសាស្ត្រមកបង្ហាត់បង្រៀនឃើញថា ជាការសមស្របម្យ៉ាងដែរ ។

តាមការពិតនោះ វាយ៉ាងដូច្នេះទេ ។ ដំបូងលោកគ្រូ - អ្នកគ្រូគួរយល់ថា តើអ្វីដែលកំនត់អោយលោកគ្រូ - អ្នកគ្រូ ជ្រើសរើសយកវិធីសាស្ត្រនេះ រឺវិធីសាស្ត្រនោះមកបង្ហាត់បង្រៀន ? នោះគឺ ខ្លឹមសារមេរៀនវាបានកំនត់គោលបំនងមេរៀន ដែលលោកគ្រូ - អ្នកគ្រូចង់បានពោលគឺអ្វីដែលត្រូវអោយសិស្សទទួលយក រឺអ្វីដែលត្រូវនាំសិស្សទៅដល់ក្នុងគោលបំនងឆ្លើយតបនឹងទិសដៅនៃការអប់រំ ( រឺគោលដៅនៃការអប់រំ ) ។ ក្រោយពីកំនត់បាននូវគោលបំនងមេរៀនរួចហើយ លោកគ្រូ - អ្នកគ្រូ ត្រូវជ្រើសរើសវិធីសាស្ត្របង្រៀនណាដែលឆ្លើយតបទៅនឹងគោលបំនងនៃមេរៀននោះ រឺគេអាចនិយាយថា ខ្លឹមសារមេរៀនវាបានកំនត់វិធីសាស្ត្របង្រៀនក៏បានដែរ ។ ប្រការនេះ មានលោកគ្រូ - អ្នកគ្រូមួយចំនួនយល់ច្រលំថា លោកគ្រូ - អ្នកគ្រូជាអ្នកកំនត់វិធីសាស្ត្របង្រៀន រឺកំនត់គោលបំនងមេរៀនដោយពុំចាំបាច់គិតដល់ខ្លឹមសារមេរៀននោះឡើយ ។ បើស្តាប់មួយភ្លែតទៅឃើញថា ហាក់ដូចជាត្រឹមត្រូវ ព្រោះអ្វីៗ ទាំងអស់ គឺលោកគ្រូ - អ្នកគ្រូជាអ្នកបញ្ជារៀបចំចាត់តាំងសកម្មភាពនៅក្នុងថ្នាក់ ។ តាមពិត តួនាទីរបស់លោកគ្រូ - អ្នកគ្រូ ពិតជាមានសារសំខាន់ណាស់មែនហើយ តែការកំនត់គោលបំនងមេរៀន រឺការជ្រើសរើសវិធីសាស្ត្របង្រៀន ដែលលោកគ្រូ - អ្នកគ្រូជាអ្នកធ្វើនោះគ្រាន់តែជាការសំរបសំរួលឆ្លើយតបទៅនឹងខ្លឹមសារមេរៀនតែប៉ុណ្ណោះ ពោលគឺខ្លឹមសារមេរៀនបានបញ្ជាដល់លោកគ្រូ -អ្នកគ្រូដែលត្រូវធ្វើយ៉ាងនេះ រឺយ៉ាងនោះ ។ ដូចនេះ ការកំនត់គោលបំនងមេរៀន និងការជ្រើសរើសវិធីសាស្ត្របង្រៀនអោយបានសមស្រប និងត្រឹមត្រូវ ចាំបាច់លោកគ្រូ - អ្នកគ្រូ ត្រូវក្តាប់ខ្លឹមសារមេរៀនអោយបានច្បាស់លាស់ជាមុនសិន ។

ដើម្បីក្តាប់ខ្លឹមសារមេរៀនអោយបានស៊ីជំរៅ លោកគ្រូ - អ្នកគ្រូ ត្រូវអានមេរៀនអោយបានច្រើនដង អានហើយអានទៀត ដើម្បីចូលជ្រៅទៅក្នុងខ្លឹមសារមេរៀន តើមេរៀនមានអត្ថន័យដូចម្តេចហើយមានបញ្ហាអ្វីខ្លះ ? អ្វីដែលត្រូវអោយសិស្សក្រេបជញ្ជក់យកពុទ្ធិពីមេរៀន ? ហើយអ្វីនោះ វាសមស្របនឹងគោលដៅនៃការអប់រំទូទៅ ឆ្លើយតបទៅនឹងការកសាងបុគ្គលិកលក្ខណៈរបស់សិស្ស រឺទេ ? ក្តាប់បានបញ្ហាទាំងអស់នេះ លោកគ្រូ - អ្នកគ្រូ ត្រូវដាក់គោលបំនងមេរៀនអោយបានសមស្រប ។

## ដូចម្តេចហៅថា គោលបំណងមេរៀន ?

គោលបំណងមេរៀន គឺជាចំនុចសំខាន់មួយ ដែលសិស្សត្រូវធ្វើដំណើរទៅដល់ រឺជាពុទ្ធិដែលសិស្សត្រូវទទួលយក ដោយគ្រប់ជញ្ជក់ចេញពីមេរៀន ដើម្បីបំរើដល់ការកសាងបុគ្គលិកលក្ខណៈរបស់សិស្ស ។

នៅក្នុងកម្មវិធីសិក្សា ទោះបីនៅបឋមសិក្សាក្តី មធ្យមសិក្សាក្តី រឺនៅឧត្តមសិក្សាក្តី មានមុខវិជ្ជាឯកទេសច្រើនបែប ដែលទាំងអស់សុទ្ធតែបានរួមចំណែកដល់ការកសាងបុគ្គលរបស់សិស្ស - និស្សិត ។ នៅក្នុងមុខវិជ្ជាឯកទេសនីមួយៗ មានមេរៀនច្រើនបែបយ៉ាងទៀត ហើយពោរពេញទៅដោយខ្លឹមសារប្លែកៗ និងសំបូរបែប ។ ខ្លឹមសារសំបូរបែបនេះ មានគោលបំណងអប់រំប្លែកៗ គ្នា ដែលតំរូវអោយលោកគ្រូ - អ្នកគ្រូជ្រើសរើសវិធីសាស្ត្រប្លែកៗ គ្នាយកមកបង្ហាត់បង្រៀនដែរ ។ លោកគ្រូ - អ្នកគ្រូអាចជ្រើសរើសយកវិធីសាស្ត្រនេះ រឺជ្រើសរើសយកវិធីសាស្ត្រនោះមកបង្រៀនដោយសេរី តែពុំមែនតាមទំនើងចិត្តរបស់ខ្លួននោះឡើយ ។ ការជ្រើសរើសវិធីសាស្ត្របង្រៀន ត្រូវអោយសមស្របឆ្លើយតបនឹងខ្លឹមសារមេរៀន និងគោលបំណងមេរៀន ។ មេរៀនមួយ គេអាចបង្រៀនតាមវិធីសាស្ត្រច្រើនយ៉ាងតាមវិធីសាស្ត្រនេះ រឺវិធីសាស្ត្រនោះ អាស្រ័យទៅតាមការជ្រើសរើសរបស់លោកគ្រូ - អ្នកគ្រូ ។ ចំនុចសំខាន់នោះ គឺលោកគ្រូ - អ្នកគ្រូ ត្រូវពិនិត្យទៅដល់គោលដៅដែលត្រូវទៅដល់ ។ ឧទាហរណ៍ ដូចជាយើងត្រូវចេញដំណើរពីចំនុច « ក » ទៅចំនុច « ខ » យើងអាចធ្វើដំណើរដោយផ្លូវត្រង់ រឺធ្វើដំណើរដោយផ្លូវកិចកុង តែចុងក្រោយយើងទៅដល់ចំនុច « ខ » ដោយសុវត្ថិភាពដូចគ្នា ។ ក្នុងន័យនេះ លោកគ្រូ - អ្នកគ្រូ ត្រូវមានគំនិតច្នៃប្រឌិតដោយប៉ិនប្រសប់ក្នុងការជ្រើសរើសវិធីសាស្ត្រយកមកបង្ហាត់បង្រៀន ។

## ក្នុងការជ្រើសរើសវិធីសាស្ត្របង្រៀន ប្រការដែលគួរអោយព្រួយបារម្ភនោះគឺ ៖

- លោកគ្រូ - អ្នកគ្រូ បានជ្រើសរើសវិធីសាស្ត្រដដែលៗ យកទៅបង្ហាត់បង្រៀនលើមេរៀនខុសៗ គ្នា ទោះបីពេលវេលា រឺមជ្ឈដ្ឋានខុសគ្នាក៏ដោយ ។

- អស់លោក - លោកស្រី ដែលមានតួនាទីជាអ្នកត្រួតពិនិត្យលើការបង្ហាត់បង្រៀន ពុំត្រូវបង្គាប់បញ្ជាអោយលោកគ្រូ - អ្នកគ្រូបង្រៀនតាមវិធីសាស្ត្រតែមួយ ដោយមានគំនិតអោយមានការឯកភាពគ្នាទូទាំងសាលា ទូទាំងស្រុកទូទាំងខេត្តនោះឡើយ បើមានយោបល់ដូចនេះ លោកគ្រូ - អ្នកគ្រូ ពិតជាគ្មានគំនិតច្នៃប្រឌិត គ្មានលទ្ធភាពជ្រើសរើសវិធីសាស្ត្រយកមកបង្ហាត់បង្រៀនតាមគរុកោសល្យទំនើបឡើយ ។ គួរចងចាំថា វិធីសាស្ត្របង្ហាត់បង្រៀន កាលណាកាន់តែមានច្រើនពេលណា កាន់តែល្អពេលនោះ សំរាប់លោកគ្រូ - អ្នកគ្រូយើង ។ តែប្រការសំខាន់នោះ គឺយើងត្រូវចេះជ្រើសរើសអោយសមស្របនឹងខ្លឹមសារ និងគោលបំណងនៃមេរៀននីមួយៗ ដើម្បីសំរេចភារកិច្ចបណ្តុះបណ្តាលរបស់សាលារៀន ។

## ២. អំពីការអនុវត្តវិធីសាស្ត្របង្រៀន :

រួចមកហើយយើងឃើញថា វិធីសាស្ត្របង្ហាត់បង្រៀនដែលលោកគ្រូ - អ្នកគ្រូបានទទួលមានច្រើនបែបច្រើនយ៉ាង ហើយលោកគ្រូ - អ្នកគ្រូ អាចជ្រើសរើសយកវិធីសាស្ត្រនេះ រឺវិធីសាស្ត្រនោះ យកមកបង្ហាត់បង្រៀន ។ វិធីសាស្ត្រ

ទីមួយៗ សុទ្ធតែមានចំនុចខ្លាំង និងចំនុចខ្សោយរបស់ខ្លួន ។ គ្មានវិធីសាស្ត្រណាមួយដែលល្អផ្តាច់នោះឡើយ ។ វិធីសាស្ត្រទីមួយៗ សុទ្ធតែមានដំនើរការរបស់វាជាលំដាប់លំដោយ ប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ ។ ទ្រឹស្តីគរុកោសល្យទំនើប បានប្រឆាំងនឹងការអនុវត្តបែបរូបមន្តនិយម រឺ បែបគម្ពីរនិយម ។ ដូចនេះ ទោះបីវិធីសាស្ត្រទីមួយៗ មានដំនើរការរបស់វាប្លែកៗ គ្នាក៏ដោយ ក៏លោកគ្រូ - អ្នកគ្រូ ពុំត្រូវអនុវត្តតាមបែបរូបមន្តរឹងកំព្រឹសនោះឡើយ ។ ក្នុងការអនុវត្តវិធីសាស្ត្រ លោកគ្រូ - អ្នកគ្រូ ត្រូវមានគំនិតច្នៃប្រឌិតរស់រវើក ប្រកបដោយល្បិចវិធីទន់ភ្លន់ជាទីបំផុត ។

តាមធម្មតា វិធីសាស្ត្របង្ហាត់បង្រៀនដែលលោកគ្រូ - អ្នកគ្រូ ជ្រើសរើសយកមកបង្ហាត់បង្រៀនមានច្រើនយ៉ាងទៅលើកម្មវត្ថុនៃការអប់រំប្លែកៗ គ្នា និងក្នុងមជ្ឈដ្ឋានអប់រំខុសៗ គ្នា ដោយគេពុំអាចបង្រៀនសិស្សនៅមណ្ឌលខ្ពង់រាបអោយដូចនឹងការបង្ហាត់បង្រៀននៅតំបន់វាលទំនាប រឺនៅតំបន់មាត់សមុទ្រនោះឡើយ ទោះបីមេរៀនដូចគ្នាក៏ដោយ ។ ក្នុងដំនើរការបង្ហាត់បង្រៀន លោកគ្រូ - អ្នកគ្រូ ត្រូវរៀបចំសកម្មភាពរស់រវើក រឺផ្លាស់ប្តូរវិធីសាស្ត្របង្រៀនទៅតាមស្ថានភាពជាក់ស្តែងនៃថ្នាក់រៀន រឺបញ្ចូលឆ្លាស់ប្តូរគ្នាក្នុងករណីចាំបាច់ ។

សរុបមកឃើញថា លោកគ្រូ - អ្នកគ្រូ មានសិទ្ធិសេរីភាពគ្រប់គ្រាន់ ក្នុងការជ្រើសរើសវិធីសាស្ត្រ និងក្នុងការអនុវត្តវិធីសាស្ត្របង្រៀនតែកុំអោយខុស ។ កុំអោយខុសមានន័យថា កុំអោយខុសនឹងខ្លឹមសារមេរៀន គោលបំនងមេរៀន ទិសដៅនៃការអប់រំ សំនូមពរចាំបាច់របស់សង្គម និងលក្ខណៈសម្បត្តិរបស់កម្មវត្ថុនៃការអប់រំ គឺសិស្ស ។ គួរកត់សំគាល់ថា វិធីសាស្ត្រអប់រំទំនើប ដែលកំពុងអនុវត្តនៅលើសកលលោកនាពេលសព្វថ្ងៃនេះគឺការយកចិត្តទុកដាក់ដល់ការពង្រីកតួនាទីសកម្មរបស់សិស្ស ដោយចាត់ទុកសិស្សជា « **ប្រធានវិស័យភាព** » រឺ ផ្អែកលើទស្សនៈដែលយល់ថា « **សិស្សជាមជ្ឈមណ្ឌល** » ។

**ដោយបណ្ឌិត ឆ សោ**

# វិទ្យាសាស្ត្រអនុវត្ត

## ទឹក : រំហួត - ចំណិត

### ចូរអ្នករិះគិត

- ហេតុអ្វីបានជាខោអាវសើម ប្រែទៅជាស្ងួតនៅពេលគេយកវាទៅហាលសន្ទឹងកណ្តាលខ្យល់ ?
- ចុះបើគេដាក់ខោអាវសើមនោះនៅក្នុងចានបោកខោអាវ តើវាឆាប់ស្ងួតដែរ រឺទេ ?
- ដាក់ខោអាវសើមហាលថ្ងៃ និងដាក់ខោអាវសើមក្នុងម្លប់ តើមួយណាឆាប់ស្ងួតជាង ? ហេតុអ្វី ?

### យើងធ្វើពិសោធន៍

១.




យើងចាក់ទឹកក្នុងបរិមាណដូចគ្នាក្នុងចានពីរដូចគ្នា និងក្នុងថូមួយ ។ យើងគូសកំរិតទឹកក្នុងចាន និង ថូ ។

យើងដាក់ចាន **« ក »** នៅខាងក្រៅថ្នាក់ហាលថ្ងៃ ឯចាន **« ខ »** និងថូដាក់ក្នុងថ្នាក់ ។ ពីរបីថ្ងៃក្រោយមក តើអ្នកសង្កេតឃើញទឹកស្រកពីក្នុងចាន « **ក** » និង « **ខ** » និងថូខុសគ្នាដូចម្តេច ? តើអ្នកអាចទាញសេចក្តីសន្និដ្ឋានយ៉ាងណា ?

២. **យើងដាំទឹកអោយពុះ :**




ដាក់ទឹកក្នុងឆ្នាំង គ្របឆ្នាំងហើយដាំវាអោយពុះ ។ ពេលទឹកពុះ អ្នកបើកគ្របមើល តើឃើញអ្វីខ្លះ ? តើអ្នកឃើញអ្វីចេញពីឆ្នាំងទឹក ? ពេលបើកគ្របឆ្នាំងឡើង តើយើងឃើញអ្វីជាប់នៅនឹងផ្ទៃក្រោមនៃគ្របឆ្នាំងនោះ ?

៣. យើងបិតទឹក :




តើទឹកដែលស្រក់ចេញជាដំណក់ៗ នោះ មានពណ៌ដែរ រឺទេ ? មានលាយដីឥដ្ឋដែររឺទេ ? អ្នកភក់មើល តើមានជាតិប្រៃ ( អំបិល ) ដែរ រឺទេ ?

## យើងយល់

**រំហួតទឹក** : ទឹក កាលណាប៉ះនឹងខ្យល់អាកាស វាហួត : វាបំលែងទៅជាចំហាយទឹក ដែលលាយឡំទៅក្នុងខ្យល់ ។

រំហួតទឹកកាន់តែឆាប់កាលណា :
- វាកាន់តែក្ដៅ
- ផ្ទៃប៉ះជាមួយខ្យល់កាន់តែធំ
- ខ្យល់បក់កាន់តែខ្លាំង ( ខោអាវស្ងួតឆាប់ កាលណាដាក់ហាលថ្ងៃ រឺ លាតសន្ធឹង រឺមានខ្យល់បក់ខ្លាំងមកប៉ះ )

ទឹកសមុទ្រ ទន្លេ បឹង ស្ទឹងហួតឡើងទៅលើអាកាស លាយឡំជាមួយខ្យល់ ហើយបង្កើតបានជាពពក ។

**រំពុះ** : កាលណាគេដាំទឹកអោយពុះ គេឃើញពពុះកើតឡើងនៅក្នុងទឹក ហើយអណ្ដែតមកលើផ្ទៃទឹក : គេថាទឹកពុះ ។ កំរិតទឹកដែលកំពុងពុះ ចេះតែថយចុះបន្តិចម្ដងៗ ព្រោះទឹកបំលែងទៅជាចំហាយ ។ នៅលើផ្ទៃទឹកពុះ គេឃើញផ្សែងហោះចេញ ។ យកចានមកគ្របលើផ្សែងនេះ ចាននេះ នឹងជក់ដំណក់ទឹក : ចំហាយទឹកញើសទៅជាទឹកវិញ ។

**បំនិត** : កាលណាគេបិតទឹក ចំហាយទឹកដែលកើតឡើងទៅប៉ះនឹងបំពង់ត្រជាក់ ក៏កញើសទៅជាទឹក គឺចំហាយទឹកបំលែងទៅជាទឹកវិញ ។ ទឹកនេះ គឺជាទឹកបិត គ្មានរសជាតិ គ្មានពណ៌ ។

**សកម្មភាព** : ប្រមូលពត៌មានស្ដីពីការប្រើប្រាស់ទឹកបិត សំរាប់ការរស់នៅប្រចាំថ្ងៃរបស់មនុស្សយើង ។

## ត្រូវចងចាំ

ប៉ះនឹងខ្យល់ ទឹកហួតបន្តិចម្ដងៗ ។ ចំហាយទឹកដែលកើតឡើងលាយជាមួយខ្យល់អាកាស បង្កើតបានជាពពក ។

កាលណាគេដាំទឹកអោយពុះ វាបង្កើតបានជាពពុះចំហាយទឹក ដែលអណ្ដែតចេញឡើងលើផ្ទៃទឹក ។

ចំហាយទឹកដែលកញើសទៅវិញ បង្កើតបានជាទឹកបិត ។

# ការបង្រៀនមេលេខ

មេលេខជាមេរៀនមានសារៈសំខាន់ក្នុងប្រមាណវិធីគុណ និង ចែក ។

កន្លងមក ការបង្រៀនមេលេខនៅបឋមសិក្សាជាទូទៅ គ្រូតែងតែកត់តារាងមេលេខអោយសិស្សចំលង ហើយអោយខិតខំរៀនអោយបានចាំស្ទាត់ពីមេគុណ ២ រហូតដល់មេគុណ ៩ រឺដល់ ១០ តាមរបៀបមេកានិក ការបង្រៀនរបៀបនេះ ពុំបានធ្វើអោយមានគំនិតម្ចាស់ការចេះសិក្សាស្រាវជ្រាវរៀនសូត្រដោយខ្លួនឯងឡើយ ។

គេបានទទួលស្គាល់ថា ការបង្រៀនដោយយកសិស្សជាមជ្ឈមណ្ឌល អាចទទួលបានលទ្ធផលល្អប្រសើរជាងគេ ខ្ញុំបានឯកភាពលើទស្សនៈបង្រៀនសិស្ស អោយចេះរៀនខ្លួនឯង ប្រសើរជាងអោយសិស្សរង់ចាំតែទទួលពុទ្ធិពីគ្រូ ។ ក្នុងបំណងរួមចំណែកលើកកំពស់គុណភាពនៃការរៀន និង បង្រៀននៅបឋមសិក្សា ខ្ញុំសូមដកស្រង់នូវវិធីសាស្ត្របង្រៀនមេលេខដែលខ្ញុំធ្លាប់បានអោយគ្រូបង្រៀនល្បងអនុវត្តនៅសាលាបឋមសិក្សាមួយចំនួនឃើញថា អាចទទួលបានលទ្ធផលល្អ ។ វិធីសាស្ត្របង្រៀននេះ ខ្ញុំបានសរសេរក្នុងសារណាអធិការបឋមសិក្សាជំនាន់ទី ១ ដើម្បីជាជំនួយដល់លោកគ្រូ - អ្នកគ្រូ និង សិស្សានុសិស្ស នៃសាលាបឋមសិក្សាក្នុងព្រះរាជាណាចក្រកម្ពុជា និងដើម្បីសាកល្បងអនុវត្តន៍ ប្រសិនបើគេយល់ថាវិធីសាស្ត្រនេះអាចធ្វើអោយសិស្សចេះកសាងតារាងមេលេខបានដោយខ្លួនឯង ។

## វិធីសាស្ត្រដឹកនាំសិស្សរៀនមេលេខ

### ១. ការរៀបចំសំភារៈ

គ្រូ និង សិស្សគ្រប់គ្នាត្រូវមាន :

- ចង្កឹះ រឺ បំពង់បឺត ១០០ដើម
- កៅស៊ូកង ២០
- កំប៉ុងទឹកដោះគោ ២ មួយសរសេរខ្ទង់ដប់ មួយទៀតខ្ទង់រាយ

### ២. ការរៀបចំគរុកោសល្យ

- គ្រូត្រូវមានកិច្ចតែងការបង្រៀនច្បាស់លាស់
- បែងចែកសិស្សជាក្រុមតូច និងចាត់តាំងការស្វ័យគ្រប់គ្រងអោយមានវិន័យល្អ និងចេះសហការគ្នាល្អ ។

### ៣. ដំនឹកនាំមេរៀន មេគុណ ២

- សួររំលឹកពីការផ្គុំជាទសកៈ ដែលសិស្សបានរៀនរួចហើយពីថ្នាក់ទី ១
- អោយសិស្សរៀបចំកំប៉ុងដាក់លើតុពីមុខខ្លួន កំប៉ុងខ្ទង់ដប់ដាក់ខាងឆ្វេង និង កំប៉ុងខ្ទង់រាយដាក់ខាងស្តាំដៃសិស្ស ។
- អោយសិស្សចងចង្កឹះជាបាច់ក្នុង ១ បាច់ៗ ចង្កឹះ ២
- អោយសិស្សគូរតារាងមេលេខ « មេគុណ ២ »

| | | |
|---|---|---|
| ២ | ១ ដង | |
| ២ | ២ | |
| ២ | ៣ | |
| ២ | ៤ | |
| ២ | ៥ | |
| ២ | ៦ | |
| ២ | ៧ | |
| ២ | ៨ | |
| ២ | ៩ | |
| ២ | ១០ | |

- អោយសិស្សលើកចង្កើះ ១ បាច់បង្ហាញ រួចសួរសិស្ស ចង្កើះ ១បាច់មាន ២ ប៉ុន្មានដង ?
- អោយសិស្សដាក់ចង្កើះ ១បាច់នោះទៅក្នុងកំប៉ុងខ្ទង់រាយរបស់ខ្លួនគ្រប់គ្នា
- អោយសិស្សស្រាយបាច់ចង្កើះក្នុងកំប៉ុងខ្ទង់រាយរបស់ខ្លួន ហើយសួរសិស្ស តើ ២ - ១ដង ត្រូវជាប៉ុន្មានដង ?
- អោយសិស្សកត់ត្រាលទ្ធផលជាចំលើយក្នុងតារាងមេលេខរបស់ខ្លួន ។
- អោយសិស្សលើកចង្កើះ ២ បាច់បង្ហាញហើយសួរ : តើចង្កើះ ២ បាច់នេះ មាន ២ប៉ុន្មានដង ?
- អោយសិស្សដាក់ចង្កើះ ២បាច់នោះ ទៅក្នុងកំប៉ុងខ្ទង់រាយរបស់ខ្លួន ។
- សួរសិស្ស តើនៅក្នុងកំប៉ុងរាយមានចង្កើះ ២ ប៉ុន្មានដង ? អោយសិស្សស្រាយសួរទៀត តើ ២ - ២ដង ត្រូវជាប៉ុន្មាន ?
- អោយសិស្សកត់ត្រាចំលើយក្នុងតារាងមេលេខរបស់ខ្លួន ។
- អនុវត្តដូចខាងលើតទៅ រហូតដល់ ២ - ១០ ដប់ដង តែចាប់ពី ២ - ៥ ដងឡើងទៅ ដែលមានចំនួនលើស ពី ១០ ត្រូវអោយផ្តុំជាទសកៈ ចងជាបាច់ទសកៈដាក់ទៅក្នុងកំប៉ុងខ្ទង់ដប់ ។
- អោយសិស្សពិនិត្យមើលក្នុងកំប៉ុងខ្ទង់ដប់ មានប៉ុន្មានបាច់ ? ត្រូវសរសេរលេខអ្វី ? ហើយកំប៉ុងខ្ទង់រាយ មានចំនួនចង្កើះរាយប៉ុន្មាន ? ត្រូវសរសេរលេខអ្វី ? លទ្ធផលត្រូវជាប៉ុន្មាន ? ហើយអោយសិស្ស កត់ត្រាចំលើយ តាមលំដាប់លំដោយនៃចំនួនលេខរបស់តួគុណរហូតដល់កសាងបានតារាងមេលេខនោះចប់ ជាស្ថាពរ ។
- ហៅសិស្សចោះយកក្នុង ១ ក្រុមម្នាក់អោយអានតារាងមេលេខដែលខ្លួនកសាងបានរួចហើយ ជាមួយគ្នានេះ គ្រូ សរសេរតារាងមេលេខលើក្តារខៀន ។
- ហៅសិស្សក្នុង ១ ក្រុមម្នាក់មើលក្តារខៀន ហើយគ្រូប្រើវិធីលុបជាបណ្តើរៗ ដូចការបង្រៀនមេសូត្រ រួចអាន តាមក្រុម ។
- អោយសិស្សយកក្តារឈ្នួនសរសេរចំលើយតាមការសួរឆ្លាស់ចុះឆ្លាស់ឡើងរបស់គ្រូ ។
- អោយសិស្សអង្គុយតាមក្រុម គ្រូដាក់លំហាត់ វិក្ខទចំនោទដែលទាក់ទងត្រូវប្រើមេលេខនោះ
- ណែនាំអោយសិស្សខិតខំរៀនសូត្រអោយចាំស្ទាត់ និងសាកល្បងយកវិធីសាស្ត្រដែលបានរៀនរួច ទៅកសាង តារាងមេលេខដែលមានមេគុណបន្តបន្ទាប់ ។

វិធីសាស្ត្រនេះ ខ្ញុំជឿជាក់ថា យើងពិតជាបានបង្រៀនសិស្សអោយចេះរៀនដោយខ្លួនឯងបានស្របតាមវិធីសាស្ត្រដែលយកសិស្សជាមជ្ឈមណ្ឌល កសាងបាននូវភាពម្ចាស់ការ ជឿជាក់លើខ្លួនឯង និងស្រលាញ់ការសិក្សាស្រាវជ្រាវនៃសិស្សានុសិស្សរបស់យើង ដែលជាទំពាំងស្នងឫស្សីដ៏រឹងមាំនាពេលអនាគត ។

លោក **តូ គីភុក**

អធិការបឋមសិក្សាខេត្តកំពត

# ហេតុអ្វីបានជាយើងស្វាប

## ហេតុអ្វីបានជាយើងស្វាប

យើងស្វាបញឹកញាប់ នៅពេលដែលយើងមានការនឿយហត់ ។ កាលរាងកាយយើងហត់សកម្មភាពសរីរាង្គទាំងឡាយត្រូវថយចុះដោយសារយើងមិនបានបញ្ចេញអោយអស់នូវកាកសំណល់ដែលកើតនៅក្នុងសាច់ដុំនោះ ។ គឺគ្មានអ្វីក្រៅពីឧស្ម័នកាបូនិច (ក្នុងចំនោមកាកសំណល់ទាំងឡាយ ) នោះទេ ដែលបណ្ដាលអោយយើងស្វាប ។ យើងហាមាត់យ៉ាងធំ ដោយបញ្ចូលខ្យល់យ៉ាងច្រើនទៅក្នុងខ្លួន ដើម្បីរុញច្រានខ្យល់ក្នុងខ្លួនអោយចេញមកក្រៅ ។ គឺយើងបោសសំអាតឧស្ម័នកាបូនិច ។ សកម្មភាពនេះ កើតមានឡើងដោយស្វ័យប្រវត្តិ ។

យើងមានសរីរាង្គមួយនៅក្នុងខួរក្បាល ដែលរ៉ាប់រងជំណាកដង្ហើម ។ នៅពេលដែលឧស្ម័នកាបូនិច មានបរិមាណច្រើនលើសលប់នៅក្នុងខួរក្បាល សរីរាង្គនោះ អោយជំនឹងទៅសាច់ដុំដែលពាក់ព័ន្ធដល់ចលនាស្វាបនេះឯង ។

ប៉ុន្តែជួនកាល នៅពេលដែលខ្ញុំឃើញលោកគ្រូ -អ្នកគ្រូស្វាប ខ្ញុំក៏ចាប់ផ្ដើមស្វាបតាមក្រោយភ្លាម ។ តើវាជាជំងឺឆ្លង រឺយ៉ាងណា ? ក្នុងករណីនេះ ពុំមែនឧស្ម័នកាបូនិចជាអ្នកនាំអោយស្វាបនោះទេ គឺអ្វីដែលយើងឃើញ និង សំលេងដែលជាអ្នកអោយជំនឹងដល់ខួរក្បាល ហើយខួរក្បាលក៏បញ្ជាអោយសាច់ដុំធ្វើ « ការស្វាប » នោះទៅ ។

ខ្ញុំសង្ឃឹមទុកជាមុនថា លោកគ្រូ - អ្នកគ្រូនឹងស្វាបយ៉ាងតិចពីរដង នៅពេលដែលលោកគ្រូ អ្នកគ្រូ កំពុងតែអានអត្ថបទ និងរូបនេះ ។ ហ្នឹងច្បាស់ជាកំពុងតែស្វាបហើយ . . . !!!

លោក **ឈា ឈឿន**







2



## សំនួរបញ្ហា

ooo ๐ ooo

កប៉ាល់សមុទ្រមួយ បោះយុថ្កានៅកំពង់ផែ ហើយត្រូវភ្លើងឆេះ ។

នៅលើកប៉ាល់នោះ ភ្លើងកំពុងតែឆេះ ។ មានកម្មករម្នាក់ឈរនៅលើកប៉ាល់នោះ បានទទួលបញ្ជាពីប្រធានកប៉ាល់ ( Capitaine ) អោយឈរយាម ដោយមិនអោយទៅទីណាពីលើកប៉ាល់នេះឡើយ ។ ក្រុមអ្នកធ្វើការលើកប៉ាល់ទាំងអស់ ព្រមទាំងប្រធានកប៉ាល់ លោតចុះទឹក រឺជិះទូកគេចខ្លួន ។ ចំនែកកម្មករបានឈរនៅលើកប៉ាល់ដែលឆេះសន្ធោសន្ធៅតែម្នាក់ឯងតត់រហូតដល់រលត់រលាយសង្ខារជាមួយកប៉ាល់នោះទៅ ។

**សំនួរ :**

- តើកម្មករនោះ ធ្វើនេះត្រឹមត្រូវ រឺទេ ? ក្លាហានមែនរឺ ?
- តើអ្នកត្រូវធ្វើយ៉ាងណាវិញ បើអ្នកជាកម្មករនោះ ?

## សំនួរបង្កើនចំនេះដឹង

ooo ๐ ooo

### I. នៅទីក្រុងភ្នំពេញ មានផ្លូវមួយឈ្មោះ ផ្លូវព្រះបាទត្រសក់ផ្អែម។

១. ត្រសក់ផ្អែម ជានាមពិត រឺ ជាសម្មតិនាម ?

២. ត្រសក់ផ្អែម បានឡើងសោយរាជ្យពី គ.ស ប៉ុន្មាន ? ក្នុងជន្មាយុប៉ុន្មាន ? មូលហេតុអ្វី បានជាបានសោយរាជ្យ ? ព្រះអគ្គមហេសី ព្រះនាមអ្វី ? ជាបុត្រីស្ដេចគ្រងរាជ្យ រឺ ជាកូនស្រីប្រជារាស្ដ្រ ? ត្រសក់ផ្អែម ជាជនជាតិអ្វី ?

៣. ក្នុងពិធីអាពាហ៍ពិពាហ៍ នៅពេលចុងបញ្ចប់ពិធីចងដៃកូនប្រុស កូនស្រី គេតែងតែលឺអ្នកភ្លេង រឺ អ្នករាំស្រែកបន្លឺសំលេង ជ័យហោង ! សួសហោង ! បាន់អ្វីជាបន្ទាល់ ! ភ្លាមនោះ គេហៅក្រេវឡើងព្រមទាំងលើកដាវក្រវីផង ។

ឧត្បោសនសព្ទនេះ ហេតុអ្វីបានគេនាំគ្នាហៅកញ្ឆៀវសប្បាយយ៉ាងនេះ ?

### II. នៅខេត្តកណ្ដាល មានស្រុកមួយឈ្មោះស្រុក ពញាឮ

១. ពាក្យ ពញា មានប្រើពីពេលណាមក ? តើប្រើចំពោះមនុស្សប្រភេទណា ? តើពាក្យនេះ គេនៅប្រើមកទល់សព្វថ្ងៃនេះ រឺទេ ?

២. ឮជាឈ្មោះនរណា ? ហេតុអ្វីបានទទួលឋានៈជាពញា ?

# ចំលើយ - សំនួរ ក្នុងទស្សនាវដ្តីលេខ ៤

*****

ល្បះ « ចំនេះដឹងគ្មានសីលធម៌ ជាការបំផ្លិចបំផ្លាញខ្លួនឯងតែប៉ុណ្ណោះ »

**<< Science sans conscience n'est que ruine de l'âme >>**

សរសេរដោយលោក **រ៉ាប៊ីឡេ** ( **Rabelais** ) នៅស.ត ទី ១៦ ( ឆ្នាំ១៥៣២ ) សៀវភៅទី ២ ជំពូក ៨

**ឯកសារយោង** : Philosophie de l'éducation tome I page 56 par J.Leif et G.Rustin

---

សូមអានលិខិតលោក **ម៉ែន តាល់** គ្រូបង្រៀននៅសាលាបឋមសិក្សាអំពិល ភូមិអំពិល ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម នៅទំព័រទី ២៤ដែលបានផ្តល់ចំលើយដ៏ត្រឹមត្រូវ ។

គណៈកម្មាធិការនាយក ស.ប.ស.ខ បានជូនរង្វាន់លើកទឹកចិត្តចំនួនទឹកប្រាក់ ដប់ដុល្លា ( 10 $ US )

---

## ដំនោះស្រាយល្បែងជិះសេះ

ដូចក្នុងរូបខាងស្តាំនេះ គេត្រូវដាក់រូបសេះ អោយទល់ខ្នងគ្នាជាមុនសិន ។



បន្ទាប់មក គេត្រូវយករូបមនុស្សជិះសេះទៅពាសអោយបិទជិតបណ្តោយពោះ និងខ្នងសេះទាំងពីរនៃរូបខាងស្តាំនេះ ។ យើងឃើញមនុស្សពីរនាក់ជិះបំបាយសេះប្រាស់ទិសគ្នាដូចរូបខាងក្រោម ។



# ជំនឿមរណភាព

គណៈកម្មាធិការនាយកនៃស.ប.ស.ខ សូមជូនពតិមានថា ៖ ក្នុងរយៈពេលបីខែ បន្តពីខែសីហា ១៩៩៦ គឺចាប់ពីខែ កញ្ញា ១៩៩៦ ដល់ដំនាច់ខែ វិច្ឆិកា ១៩៩៦ សមាជិក សមាជិកា យើងបានទទួលអនិច្ចកម្មមានកំនើនទាំងអស់ចំនួន : **៨៣ នាក់** ។ រីឯគូស្រករ ( ប្ដី រឺ ប្រពន្ធ ) ចំនួន : **៦១ នាក់** ដូចតារាងខាងក្រោម ៖

| ល.រ | ឈ្មោះខេត្ត | ចំនួនសព សមាជិក | ល.រ | ឈ្មោះខេត្ត | ចំនួនសព សមាជិក | ផ្សេងៗ |
|---|---|---|---|---|---|---|
| | មន្ទីរក្រសួងអប់រំយុវជននិងកីឡា | | ១១ | ខេត្ត ស្វាយរៀង | ០៦ នាក់ | |
| ០១ | + អង្គភាពចំណុះ | ០៣ នាក់ | ១២ | ខេត្ត ព្រៃវែង | ១២ នាក់ | |
| ០២ | ខេត្ត តាកែវ | ០៧ នាក់ | ១៣ | ខេត្ត បាត់ដំបង | ០៣ នាក់ | |
| ០៣ | ខេត្ត កំពង់ធំ | ០៤ នាក់ | ១៤ | ខេត្ត កំពង់ឆ្នាំង | ០៤ នាក់ | |
| ០៤ | ខេត្ត សៀមរាប | ០៣ នាក់ | ១៥ | ខេត្ត កំពង់ស្ពឺ | ០៣នាក់ | |
| ០៥ | ខេត្ត កណ្ដាល | ០៤ នាក់ | ១៦ | រាជធានីភ្នំពេញ | ១៦ នាក់ | |
| ០៦ | ខេត្ត កំពង់ចាម | ១០ នាក់ | ១៧ | ខេត្ត ពោធិសាត់ | ០១ នាក់ | |
| ០៧ | ខេត្ត បន្ទាយមានជ័យ | ០៧ នាក់ | ១៨ | ខេត្ត ស្ទឹងត្រែង | ០០ នាក់ | |
| ០៨ | ខេត្ត កំពត | ០១ នាក់ | ១៩ | ខេត្ត កោះកុង | ០២ នាក់ | |
| ០៩ | ខេត្ត ក្រចេះ | ០៥ នាក់ | ២០ | ខេត្ត រតនគិរី | ០១ នាក់ | |
| ១០ | ក្រុងព្រះសីហនុ | ០១ នាក់ | ២១ | ខេត្ត មណ្ឌលគិរី | ០០ នាក់ | |
| | | សរុប : | | | **៨៣ នាក់** | |

| ល.រ | ឈ្មោះខេត្ត | ចំនួនសពគ្រួសារ ប្ដី រឺ ប្រពន្ធ | ល.រ | ឈ្មោះខេត្ត | ចំនួនសពគ្រួសារ ប្ដី រឺ ប្រពន្ធ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | មន្ទីរក្រសួងអប់រំ យុវជន និងកីឡា | | ១១ | ខេត្ត ស្វាយរៀង | ០៤ នាក់ | |
| ០១ | + អង្គភាពចំណុះ | ០១ នាក់ | ១២ | ខេត្ត ព្រៃវែង | ១៤ នាក់ | |
| ០២ | ខេត្ត តាកែវ | ០៤ នាក់ | ១៣ | ខេត្ត បាត់ដំបង | ០២ នាក់ | |
| ០៣ | ខេត្ត កំពង់ធំ | ០៥ នាក់ | ១៤ | ខេត្ត ព្រះវិហារ | ០០ នាក់ | |
| ០៤ | ខេត្ត សៀមរាប | ០៤ នាក់ | ១៥ | ខេត្ត កំពង់ឆ្នាំង | ០៣នាក់ | |
| ០៥ | ខេត្ត កណ្ដាល | ០៤ នាក់ | ១៦ | ខេត្ត កំពង់ស្ពឺ | ០៩ នាក់ | |
| ០៦ | ខេត្ត កំពង់ចាម | ០៦ នាក់ | ១៧ | រាជធានីភ្នំពេញ | ០២ នាក់ | |
| ០៧ | ខេត្ត បន្ទាយមានជ័យ | ០៥ នាក់ | ១៨ | ខេត្ត ពោធិសាត់ | ០០ នាក់ | |
| ០៨ | ខេត្ត កំពត | ០៥ នាក់ | ១៩ | ខេត្ត ស្ទឹងត្រែង | ០០ នាក់ | |
| ០៩ | ខេត្ត ក្រចេះ | ០២ នាក់ | ២០ | ខេត្ត កោះកុង | ០០ នាក់ | |
| ១០ | ក្រុងព្រះសីហនុ | ០១នាក់ | ២១ | ខេត្ត រតនគិរី | ០០ | |
| | | សរុប : | | | **៦១ នាក់** | |

រោងពុម្ព ក្រសួងអប់រំ